# ការសម្ភាសរបស់អ៊ុំស្រីយឹម ពៅ

**កៈ អ្នកធ្វើការសម្ភាសឈ្មោះ ហេខ សុជីវី          ខៈ អ្នកត្រូវគេសម្ភាសឈ្មោះ យឹម ពៅ**

កៈ ចាស! ជាដំបូងសូមជំរាបសួរអ៊ុំ!

ខៈ ចាស!ជំរាបសួរខ្មួល!

កៈ អ៊ុំខ្ញុំមកពីគំរោងរបស់ខាងសាលា BYU នៅសហរដ្ឋអាមេរិចដែលខ្ញុំមកនេះខ្ញុំបានចូលការងារស្មាគចិត្តរបស់គំរោងសាលាដើម្បីមកសំភាសន៍ប្រជាជនកម្ពុជាដែលគាត់មានអាយុ ៣៥ឡើងហើយគេសំភាសន៍នឹងគឺគេចង់ចង់ក្រង់ជាឯសារដើម្បីអោយអ្នកជំនាក់ក្រោយដែលបានស្តាប់សំលេងរបស់អ៊ុំនៅថ្ងៃនេះបានដឹងហើយមួយទៀតការសំភាសន៍គឺធ្វើឡើងដើម្បីចង់ដឹងពីប្រវត្តិរបស់អ៊ុំនឹងបទពិសោធន៍ដែលអ៊ុំបានឆ្លងកាត់បានកន្លងមកនៅក្នុងជីវិតរបស់អ៊ុំផ្ទាល់។ ចាស!ចឹងហើយថ្ងៃនេះខ្ញុំមានឪកាសដើម្បីសំភាសន៍អ៊ុំដូចនេះតើអ៊ុំផ្តល់ឪកាសនេះដើម្បីនឹងសំភាសន៍អ៊ុំដែលឬដែរទេ?

ខៈ ចាស!ខ្ញុំអោយខ្មួលដើម្បីនឹងធ្វើការសំភាសន៍អ៊ុំ។

កៈ ចាស!អរគុណអ៊ុំនឹងជាដំបូងអ៊ុំមានឈ្មោះអ្វីដែល?

ខៈ ខ្ញុំរបស់ខ្ញុំគឺមានឈ្មោះថា យឹម ពៅ។

កៈ ចាស! អ៊ុំឈ្មោះអ៊ុំម្តងទៀតបានដែលឬទេអ៊ុំ?

ខៈ ចាស! ឈ្មោះខ្ញុំគឺមានឈ្មោះថាយយឹម ពៅ។

កៈ ចាស! ឈ្មោះអ៊ុំគឺមានឈ្មោះថាអ៊ុំយឹមពៅចឹងតើឈ្មោះនេះត្រូវជាមួយនឹងអត្តសញ្ញាណប័ត្ររបស់អ៊ុំដែលឬទេអ៊ុំ?

ខៈ ចាស! ឈ្មោះនេះគឺដូចគ្នានឹងអត្តសញ្ញាណប័ត្រទាំងអស់នឹង។

កៈ ចាស!ចឹងឆ្នាំនឹងអ៊ុំមានអាយុប៉ុន្មានឆ្នាំហើយអ៊ុំ?

ខៈ ខ្ញុំនៅឆ្នាំនេះមានអាយុ៥៧ឆ្នាំហើយ។

កៈ ហើយអ៊ុំមាននៅចាំថ្ងៃខែឆ្នាំរបស់ខ្លួនឯងដែលឬទេ?

ខៈ ចាសខ្ញុំបាននៅចាំថ្ងៃខែឆ្នាំរបស់ខ្លួនឯងបានព្រោះការនឹងខ្ញុំនៅតូចដែរចឹងដូចជាមិនច្បាស់នោះទេពេលនឹងគេដាក់ដូចជា១៩៦០អីនឹង ប៉ុន្មាននោះទេទាល់តែទៅមើលក្នុងអត្តសញ្ញាណប័ត្រអីណ៎ ឥឡូវនឹងខ្ញុំបានភ្លិចបាត់ទៅហើយនឹង។ កាលនឹងនៅពេលជំនាន់អាពតនឹងខ្ញុំបាននៅជាមួយឪពុកម្ដាយហើយតែឥឡូវនឹងខ្ញុំបាននៅជាមួយនឹងក្មួយស្រីដែលប៉ុន្តែឥឡូវនឹងក្មួយស្រីនឹងឥឡូវនឹងវាបានស្លាប់ទៅបាត់ទៀតនឹង។

កៈ ហ៊ឺ!

ខៈ ឥឡូវនឹងខ្ញុំនៅតែម្នាក់ឯងនឹង។

កៈ ចាស!ចឹងបងប្អូនអ៊ុំមានប៉ុន្មាននាក់ដែលកាលពីមុននោះ?

ខៈ បងប្អូនខ្ញុំនឹងកាលនឹងខ្ញុំមានបងប្អូនចំនួន៥នាក់នឹងហើយស្រី៤នាក់ហើយប្រុសចំនួន១នាក់នឹង។

កៈ គាត់មានឈ្មោះអីខ្លះទៅអ៊ុំ?

ខៈ ពួកគេមានឈ្មោះថាយឹម អី មានឈ្មោះថាយឹមម៉ៅ ហើយយឹម ពេ យឹមប្រុស យឹមនារតីនឹងខ្ញុំនឹងមានឈ្មោះថាយឹមពៅនឹងចឹងទៅហើយចឹងសរុបមានបងប្អូនចំនួន៥នាក់នឹង។

កៈ ចាស!

ខៈ កាលនឹងបងប្អូនខ្ញុំនឹងបានស្លាប់នៅក្នុងជំនាន់អាពតចំនួន៣នាក់ហើយនៅសល់ដល់ឥឡូវនឹងមាន១នាក់ទៀតដែលបានរួចពីជំនាន់អាពតមកនោះ។

កៈ ចាស!ហើយចឹងបងប្អូនអ៊ុំមានបានរៀបអាពាហ៍ពិពាហ៍ហើយបានប៉ុន្មានគ្រួសារដែរ?

ខ៖ បងប្អូនដែលនៅក្នុងជំនាន់អាពតនឹងគេមិនទាន់បានរៀបការចំនួន៣នាក់នឹងហើយគេបានស្លាប់អស់ទៅនឹងពួកគាត់មិនទាន់បានរៀបការនៅឡើយនោះទេតែដល់នៅសម័យនេះបានរៀបការទាំង២នាក់នឹងមានខ្ញុំហើយទៅ១ទៀតនឹងមីប្អូនខ្ញុំនឹងគេបានរៀបការហើយដែលតែក្រោយមកគេបានស្លាប់ទៅគេទឹមតែស្លាប់ទៅដែលទេហើយកូនគេនឹងនៅមានជីវិតនឹងប្តីចឹងទៅប៉ុន្តែឥឡូវនឹងគេបានទៅណាទៅនៃអីចឹងទៅមិនបាននៅជុំគ្នានោះទេហើយអ៊ុំនឹងក៏មិនបានដឹងថាគេទាំង២នាក់កូននឹងអូនថ្លៃនឹងក៏មិនដឹងគេទៅណាព្រោះអីគេមិនបានប្រាប់ខ្ញុំអោយបានដឹងនោះទេអូនអើយវាចឹងទៅឯង។

ក៖ ចាស!ចឹងបងមានតែម្នាក់ឯងទេសព្វថ្ងៃព្រោះបងប្អូនបង្កើតបងបានស្លាប់អស់ហើយ?

ខ៖ ចាស!នឹងហើយសព្វថ្ងៃនឹងអ៊ុំនៅតែឯងគត់តែម្តងនឹង។

ក៖ ចុះឪពុកម្តាយរបស់អ៊ុំវិញ?

ខ៖ អូ! ពួកគាត់នឹងបានស្លាប់នៅក្នុងជំនាន់ពពតទាំងអស់នឹងហើយ។

ក៖ ចឹងតើអ៊ុំនៅចាំឈ្មោះរបស់ពួកគាត់ដែរឬទេអ៊ុំ?

ខ៖ ឈ្មោះម្តាយរបស់ខ្ញុំគាត់មានឈ្មោះថានាងនឹងហើយឪពុក យឹម ប៉ុម ហើយម្តាយខ្ញុំនឹងគាត់មានឈ្មោះថានាងចឹងហើយតែមិនបានដឹងថាអីគេនាងនោះទេឈ្មោះត្រកូលរបស់គាត់អ៊ុំមិនបានចាំនោះទេក្មួយអើយ។

ក៖ ចាស

ខ៖ ព្រោះអីបានជាអ៊ុំនឹងមិនបានចាំនោះព្រោះតែនៅពេលឥឡូវនឹងមានបងប្អូនដាក់នាមត្រកូលជាឈ្មោះរបស់នាមត្រកូលខាងឪពុកចឹងហើយអ៊ុំនឹងនៅចាំតែចំណែកឯនាមត្រកូលរបស់អ្នកម្តាយរបស់អ៊ុំវិញនោះអ៊ុំមិនបានដឹងទេកាលនឹងនោះ ហើយទៅខាងម្តាយនឹងអ៊ុំមិនបានដឹងទេព្រោះកាលគាត់នៅរស់នឹងគាត់មិនបាននាំទៅស្រុកគាត់ហើយទៅស្គាល់បងប្អូនរបស់គាត់ផងនឹងក្មួយអើយកាលនឹងនោះ ចឹងទៅណាបានពេលដែលទទួលមានជំនាន់អាពតនឹងគេបានចូលមកនៅក្នុងប្រទេសកម្ពុជាយើងចឹងទៅស្រាប់តែយើងនឹងត្រូវបានបែកគ្នាចឹងទៅហើយម្តាយក៏គាត់ឈឺកាលនឹងហើយអ៊ុំនៅតូចដែលចឹងក៏មិនបានទៅសួរគាត់រឿងបងប្អូន

នឹងឈ្មោះនាមត្រកូលរបស់គាត់ចឹងទៅ ចឹងហើយកាលនឹងយើងមិនបានស្គាល់រហូតមកដល់សព្វថ្ងៃនឹងព្រោះគាត់ទាំង២នាក់នឹងគាត់បានស្លាប់ទាំង២នៅនឹងកាលជំនាន់អាពតនឹងទាំង២នាក់ទៅហើយក៏ពត៍មាននឹងវាបានភ្លេចបាត់ចឹងទៅដែលតែអ៊ុំនៅមានម្ដាយធំម្នាក់ហើយខាងឯម្នាក់ខ្ញុំដែលខ្ញុំបានស្គាល់នឹងតែវាមិនបានដឹងអីបើម្ដាយធំខ្ញុំនឹងគាត់ក៏បានស្លាប់ទៅដែលកាលនៅឯជំនាន់អាពតនឹងនោះ។ ហើយពេលដែលបានបែកអាពតហើយនឹងខ្ញុំមាននៅសល់តែបងប្អូន២នាក់ទេគឺខ្ញុំនឹងហើយនឹងមានប្អូនស្រីម្នាក់ទៀតតែឥឡូវនឹងប្អូនខ្ញុំនឹងគេបានស្លាប់បាត់ទៅក៏ឥឡូវនឹងខ្ញុំនៅតែម្នាក់ឯហើយឥឡូវនឹងនោះ។

ក៖ ហើយប៉ុន្តែបងប្អូនខាងឪពុករបស់អ៊ុំនៅមានជីវិតទេ?

ខ៖ នៅខ្លះមិនច្រើននាក់នោះទេ។

ក៖ ចាស!ចឹងអ៊ុំ មានបានស្គាល់ពួកគាត់ដែលឬទេអ៊ុំ?

ខ៖ អ៊ុំបានស្គាល់ចឹងហើយបានជាអ៊ុំនឹងបានដឹងប្រវត្តិនោះនឹងអី។

ក៖ តើពួកគាត់មានឈ្មោះអ្វីខ្លះទៅអ៊ុំ?

ខ៖ ឈ្មោះបងរបស់គាត់ឈ្មោះយឹម សយ យឹមអី....អ៊ុំស្គាល់តែបងប្អូនគាត់បង្កើតទេតែចំណែកឯក្មួយៗរបស់គាត់វិញនឹងមានឈ្មោះថាយឹមថាច យឹមអីចឹងទៅណាហើយបើបងគាត់បង្កើតផ្សេងៗទៀតនឹងអ៊ុំមិនបានចាំទេអ៊ុំចាំតែនាមត្រកូលគាត់នឹង អត់បានដឹងថាគាត់មានឈ្មោះអីនោះទេព្រោះកាលនឹងគាត់ជាទាហានហ៎ គាត់បានធ្វើជាទាហានចឹងហើយកាលនឹងពីសង្គមយើងនឹងដល់ចឹងហើយគាត់បានបែកបាក់ក្រុមគ្រួសាររបស់គាត់ដែលដល់ចឹងទៅគាត់មិនដឹងទៅណាហើយយើងនឹងក៏មិនបានដឹងគាត់ដែលនឹងមិនដឹងអីៗខ្លះទេ។ ហើយកាលនឹងអ៊ុំបានចាំតែពេលដែលបែកពីអាពតមកនឹងអ៊ុំបានទៅនៅជាមួយនឹងបងប្អូនបង្កើតត្រូវជាបងរបស់ឪពុកបងនឹងមួយរយ:ដល់ហើយទៅបងនឹងក៏បានបែកជាមួយនឹងគាត់មួយរយ:ហើយក៏លឺថាគាត់ស្លាប់ទៅហើយម្ដាយធំគាត់ក៏ស្លាប់ដែលទៅកាលនឹងនៅជំនាន់អាពតពេលដែលបានបែកហើយនឹងនោះខាងឪពុកចំណែកឯខាងម្ដាយវិញគាត់បានស្លាប់នៅក្នុងជំនាន់អាពតជាមួយនឹងគាត់ជាអ្នកម្ដាយខ្ញុំនឹងផ្ទាល់តែម្ដង។

ក៖ ចាស! ចឹងម្ដាយធំរបស់អ៊ុំនឹងគាត់មានឈ្មោះអ្វីដែលអ៊ុំ?

ខ៖ ម្ដាយធំខាងឪពុកនឹងគាត់មានឈ្មោះថា យឹមសយ ហើយម្ដាយធំខាងម្ដាយខ្ញុំនឹងគាត់មានឈ្មោះថាគាត់មានឈ្មោះថានាងដែលតែមិនបានដឹងថាអីគេនាងនឹងទេហើយម្ដាយធំខ្ញុំនឹងគាត់មានឈ្មោះថាមុំតែមិនបានដឹងថាអីគេមុំនឹងដែលនឹង២នាក់បងប្អូនគាត់នឹងនោះគាត់បានទៅជំលៀសជាមួយនឹងគ្នាទៅហើយឪខ្ញុំនឹងគាត់ក៏បានទៅជំលៀសនៅតំបន់ឆ្ងាយដែលចេះតែគេអោយទៅហើយចេះតែទៅហើយកាលនឹងនោះដល់ណានៃខ្លះទេ ន់រហូតទៅដល់ភ្នំស្រុកស្វាយស៊ីសមផុន នរគបុរី ភ្នំស្រុកហួសទៅទីនោះទៀតហើយទៅចូលទៅក្នុងនឹងហើយពេលដែលទើរត្រឹមនៅនឹងនៅឯជុំរុំនៅឯជិតថៃឯនោះ ហើយបើកាលនឹងបើខ្ញុំមានបងប្អូននៅថៃនឹងខ្ញុំត្រូវទៅនៅឯស្រុកក្រៅនឹងបាត់ទៅហើយ ហើយពេលនឹងអីខ្ញុំនឹងបានទៅអាមេរិកអីយូរណាស់ហើយតែពេលនឹងអ៊ុំនឹងវាអត់ហ៊ានព្រោះពេលដែលចេញមកពីអាពតនឹងខ្ញុំបានបណ្ដើរប្អូនខ្ញុំដែលវាទឹមតែស្លាប់ទៅនឹងហើយកាលនឹងចេញពីព្រៃមក២នាក់បងប្អូន ហើយចឹងមិនដឹងហ៊ានទៅហើយចឹងហើយក៏បានលឺពាក្យគេប្រាប់ទៀតថាទៅមុខទៅនឹងមានរន្ធដៅ១ដែលគេជីកសំរាប់តែអ្នកដែលជាប្រជាជនថ្មីនឹងសំលាប់នៅក្នុងរន្ធដៅនឹងឯ។

ក៖ ហឺ!

ខ៖ ហើយអ្នកដែលបានជីករន្ធដៅនឹងហើយគេបានវៃចោលទៅបាត់ហើយមានន័យថាគេបានយកទៅសំលាប់ចោលបាត់ហើយនឹងចឹងហើយដល់ពេលដែលអ៊ុំលឺគេនិយាយចឹងហើយនឹងក៏មិនហ៊ានទៅបែរជាទៅតាមគេចូលក្នុងព្រៃចូលទៅកាត់ស្ទឹងមកឯសៀមរាបយើងវិញមកចេះតែបានមកហើយកាលនឹងនោះហើយចេះតែដេកនៅតាមផ្លូវរហូតមកហើយកាលនឹងបានកងទព័ជនជាតិវៀតណាមគេនឹងបានគេឃើញយើងចឹងក៏គេបានហៅយើងមកជូនយើងដាក់ត្រឹមស្ដង់ទៅហើយដល់ពេលដែលបានដើរឆ្លងកាត់ស្ដង់ហើយនឹងត្រូវឆ្លងកាត់វាលស្រែរហូតមកដល់ផ្សារដីហុយមករហូតមក។

ក៖ ហឺ!

ខ៖ ចឹងហាហ់ប្រវត្តិមីងនឹងវាកំសក់ណាស់ហើយក៏បាននៅជាមួយគេមួយរយៈចឹងហើយពេលនឹងអ៊ុំត្រូវទៅយកស្រូវគេនៅតាមខេត្តចឹងហើយអ៊ុំនឹងត្រូវតែដើបមកពេលយប់មកសំរាប់ទៅយកស្រូវគេហើយកាលនឹងអ៊ុំត្រូវដើរជាមួយនឹងគេជាមួយនឹងអ្នកផ្សេងៗដែលមិនដែលស្គាល់សោះហើយពេលដែលបានស្រូវហើយនឹងអ៊ុំនឹងក៏បានយកមកដាក់ក្នុងបាវចឹងទៅសំរាប់

ទុកដាក់សំរាប់ទុកហូបចឹងទៅណាហើយកាលនឹងអ៊ុំសន្សំច្រក់ទុកដល់ពេលបានច្រើនទៅគេមិនអោយយើងនៅជាមួយគេទៀតនឹង។និយាយទៅប្រវត្តិរបស់អ៊ុំនឹងវាកំសត់ណាស់។

ក៖ ចាស!ចឹងដល់ពេលហើយទៅអ៊ុំមានក្រុមគ្រួសារដែលឬទេ?

ខ៖ ខ្ញុំមានក្រុមគ្រួសារមានប្តីមានកូនមានចៅនឹងឥឡូវនឹងនោះ។

ក៖ ចឹងប្តី របស់អ៊ុំ គាត់មានឈ្មោះអ្វីដែរ?

ខ៖ គាត់មានឈ្មោះថា ញ៉ែម ខែមរៈ ញ៉ែមខែមរៈនឹងគាត់ជាមន្រ្តីរាជការដែលគាត់ដើរទៅធ្វើផ្លូវអោយគេ តែគាត់អាត្រែតហើយតែគេចេះតែហៅគាត់អោយទៅជួយធ្វើការងារនឹងទៅពេលដែលគេហៅទៅនឹងគេហៅគាត់ខាងក្រៅទេសំរាប់រកលុយខាងក្រៅនោះទេសំរាប់បានលុយចាយដែលប៉ុន្តែសព្វថ្ងៃនឹងគាត់បានអាត្រែតហើយនឹង។

ក៖ ចាស!ចឹងសព្វថ្ងៃនឹងគាត់នៅបន្តការងារគាត់ដ៏ដែល?

ខ៖ ចាស!នៅតែចុះតាមខេត្តហើយគាត់នៅតែចុះធ្វើអោយគេដ៏ដែលចឹងទៅ។

ក៖ ហឺ! ចឹងដល់ពេលចឹងអ៊ុំដល់ពេលចឹងតើលោកពូគាត់ចុះតាមខេត្តចឹងទៅតើគាត់បានមកផ្ទះរាល់ថ្ងៃដែលឬទេ?

ខ៖ គាតបានមកផ្ទះនឹងយូរម្តងទេពេលដែលគាត់ធ្វើការនៅជិតៗនឹងទៅគាត់១ថ្ងៃគាត់បានមកម្តងចឹងទៅ តែបើថាគាត់ទៅធ្វើការដល់ព្រៃវែងអីចឹងទៅគាត់២ទៅ៣ថ្ងៃបានគាត់មកម្តងចឹងទៅណាគាត់យូរបានគាត់បានមកផ្ទះ។ត្រូវជាថ្ងៃណាគាត់នឹកឃើញចង់មកលេងចៅម្តងអីចឹងទៅគាត់បានមកទៅ ហើយពេលចឹងកាត់បានមកនៅពេលយប់ចឹងទៅហើយដល់ពេលព្រឹងឡើងចឹងទៅគាត់បានទៅវិញចឹងទៅ។

ក៖ ចឹងអ៊ុំប្រាកដជានឹងគាត់ហើយចឹងនោះ?

ខ៖ យើងចាស់ហើយចឹងវាជារឿងធម្មតាហើយតែចំណែកកូនចៅវិញគេនឹងហើយអ៊ុំឥឡូវនឹងគ្មាននឹកអីទេ។

ក៖ ចឹងអ៊ុំសព្វថ្ងៃនឹងអ៊ុំមានកូនប៉ុន្មាននាក់ដែល?

ខ៖ អ៊ុំមានកូនចំនួន៤នាក់ស្រី៣ប្រុស១។

ក៖ ចាស!ហើយពួកគាត់ទាំងអស់គ្នាមានឈ្មោះអីខ្លះទៅអ៊ុំ?

ខ៖ ពួកគេមានឈ្មោះថា ញ៉ែមគុណធា ញ៉ែមគុណធី ញ៉ែមចំរើន ញ៉ែមរតនា មាន៤នាក់នឹង។

ក៖ តើពួកគាត់ទាំងអស់គ្នានឹងមានបានរៀបអាពាហ៍ពីពាហ៍ប៉ុន្មាននាក់ហើយ?

ខ៖ បាន៣នាក់ហើយនូវកូនប្រុស១ដែលមិនទាន់មានរៀបអាពាហ៍ពិពាហ៍នោះនូវកូនទី៣ដែលមិនទាន់មានរៀបការនឹងគេ។

ក៖ ចាស!ចឹងអ៊ុំមានចៅប៉ុន្មាននាក់ហើយ?

ខ៖ មានចៅ៦នាក់។

ក៖ ឈ្មោះអីខ្លះទៅអ៊ុំ?

ខ៖ ឈ្មោះ ហង់ មរកត នេះឈ្មោះហង់បញ្ញា ហើយនោះញ៉ែមស្រីលៀប ញ៉ែមស្រីលាប ហើយចៅបងនឹងមានឈ្មោះថាយ៉ែមសំណាង ចឹងទៅហើយមានឈ្មោះចៅមួយនឹងទៀតនឹងគេមានឈ្មោះថាចៅ ជុំថាកគូចឹងទៅព្រោះពេលនឹងវាកើតនៅពេលរឿនចិនដែលគេលេងអោយមើលចឹងទៅក៏បានដាក់ឈ្មោះអោយដូចជាតួឯកនៅក្នុងរឿងនឹងទៅ។

ក៖ អូ!កាលនឹងរឿងកូរ៉េ អូហឺស!

ខ៖ ហឺស!ចឹងទៅ

ក៖ ហើយពួកគាត់នឹងបានចូលរៀនបានត្រឹមថ្នាក់ទីប៉ុន្មានខ្លះដែលចឹងទៅបង?

ខ៖ អាចៅបងបានត្រឹមថ្នាក់ទី៦ហើយអាចៅទី២គេបានរៀនត្រឹមថ្នាក់ទៅ២ហើយអាចៅបន្ទាប់នឹងគេបានចូលរៀនត្រឹមថ្នាក់ទី១ចឹងហើយចៅអ៊ុំនឹងទឹមតែបានចូលរៀនបាន៣នាក់នឹងទេព្រោះអាចៅផ្សេងៗទៀតគេនៅតូចៗនឹង។

កៈ ចាស! គួរអោយស្រលាញ់មែនទែនចៅអ៊ុំហើយចឹងអ៊ុំចុះចំណែកឯកូនរបស់អ៊ុំវិញតើពួកគាត់បានសិក្សានៅ កំរិតណាដែលបានជាអ្នកគាត់សំរេចចិត្តរៀបអាពាហ៍ពិពាហ៍?ហើយសព្វថ្ងៃនឹងតើពួកគាត់មានបាននៅរៀនដែលឬទេ?

ខៈ កូនអ៊ុំនឹងវាចប់រៀនអស់ហើយ មួយនេះនឹងវាពៅគេវារៀនបានម៉ានទេវារៀនបានត្រឹមថ្នាក់ទី៧វាក៏ឈប់ទៅហើយមីងបងគេនឹងរៀនបានត្រឹមថ្នាក់ទី១១ហើយក៏គេបានឈប់ទៅហើយចំណែកឯកូនប្រុសអ៊ុំវិញនោះគេបានរៀនចប់ដល់ត្រឹមថ្នាក់ទី១២ហើយគេក៏ឈប់រៀនទៅព្រោះកាលនឹងគេបានប្រឡងជាប់ថ្នាក់ទី១២នឹងដែលតែគេគ្មានលុយដើម្បីរៀនតចឹងហើយក៏ឈប់រៀបបានត្រឹមនឹងទៅមិនបានបន្តចំណេះអីចឹងទៅណាដ៏ចឹងហើយក៏មិនបានអោយគេនឹងទៅបន្តចូលរៀនអីទៀតដែល ហើយធ្វើការនឹងគេជាមួយនឹងអង្គការគេដែលគេមកនៅតាមភូមិនឹងចឹងទៅណាដែលរើសក្មេងៗទៅណាហើយកាលនឹងវាបានទៅជួយធ្វើការងារគេខាងតខ្សែភ្លើងចឹងទៅណាហើយដល់ចឹងទៅក៏វានឹងបានចេះតខ្សែភ្លើងនឹងទៅណា។

កៈ ហើយដល់ចឹងតើសព្វថ្ងៃនឹងតើអ៊ុំមានទីលំនៅនៅក្នុងភូមិឃុំណាដែលអ៊ុំ?

ខៈ ចាស!សួរពីឥឡូវឬពីមុន?

កៈ ចាស!ទីលំនៅសព្វថ្ងៃ?

ខៈ ចាស! សព្វថ្ងៃនឹងគឺនៅនឹង សង្កាត់ឬស្សីកែវ ភូមិបឹងស្រឡា ក្រុមរថភ្លើង។

កៈ ចាស!ហើយទីលំនៅនេះគឺជាលំនៅរបស់អ៊ុំបានទិញដាច់តែម្តងឬក៏ជួលគេ?

ខៈ ចាស!ទីលំនៅនេះខ្ញុំបានទិញដាច់តែម្តងនឹង។

កៈ ចាស!

ខៈ ការទិញនឹងវាមិនទាន់មានផ្ទះដូចនេះទេមានតែព្រៃនឹងហើយកាលទិញនឹងគេលក់អោយក្នុងតំលៃ១តំឡឹង។

កៈ ចាស!ការទិញនឹងគេលក់អោយអ៊ុំក្នុងតំលៃ១តំឡឹង។

ខ៖ កាលនឹងគេមានទាំងផ្ទះនឹងដីអោយតែក្រោយមកនៅបានប្រហែលជាបានប៉ុន្មានឆ្នាំទៅវាឡើងរាងពុកផុយអស់ហើយដល់ចឹងទៅផ្ទះដែលនៅនឹងរាល់ថ្ងៃនឹងបានគេជួយដូចជាអង្គការអីនឹងគេបានជួយទេផ្ទះនេះនឹងនោះគេបានអោយជួយលើអោយបានរាងខ្ពស់ជាងមុនហើយមានរាងដូចសព្វថ្ងៃនឹងចឹងទៅ។

ក៖ តើអង្គការគេមានឈ្មោះអ្វីដែរទៅអ៊ុំ?

ខ៖ កាលនឹងអង្គការនឹងមានឈ្មោះអីដែលទៅមុំ?

គ៖ អង្គការខេរា។

ខ៖ នឹងហើយអង្គការនឹងមានឈ្មោះថាអង្គការខេរា កាលនឹងគេបានជួយហើយនឹងគេក៏ទៅវិញទៅ គេបានជួយផ្ទះមីងអីមួយចប់តែម្តងនឹង។

ក៖ តើអង្គការមួយនឹងគេបានជួយតែផ្ទះរបស់មីងឬក៏គេបានមកជួយក្នុងភូមិនេះចំពោះគ្រួសារផ្សេងៗទៀតដែរឬក៏យ៉ាងម៉េចដែរ?

ខ៖ គេជួយមើលសំរាប់ផ្ទះណាមើលទៅឃើញថាវារាងពិបាកជាងគេ មានសភាពផ្ទះលេចមុខលេចក្រោយអីចឹងទៅគេជួយហើយចំពោះផ្ទះណាដែលរាងគ្រាន់បើដែលនឹងគេមិនបានទៅជួយទេគេអត់ជួយទេគេជួយតែផ្ទះណាដែលលំបាក់ហើយមានជីវៈភាពយើងរកទីទាល់ហើយមានសភាពខ្វះមុខនឹងខ្លះក្រោយអីចឹងទៅគេក៏ជួយអោយគេមើលទៅវាលំបាកចឹងទៅគេក៏ជួយទៅ មានចឹងហើយកាលនឹងខ្ញុំមានតែផ្ទះរាងទៀម ហើយមើលទៅផ្ទះដីនៅខាងក្រោមនឹងវារាងជ្រៅណាស់កាលនឹងនោះ គេបានសន្សំអោយយើងបានចាក់ដីបានប៉ុន្មានឡានចឹងដែលហើយធ្វើបន្តន់អីមួយចប់ចឹងទៅណាហើយគេបានទៅរកស៊ីអីសំរាប់ខ្លួនយើងនឹងបានរាងគ្រាន់បើដែលនឹង ពីមុននឹងបានជាគេថាយើងនឹងវារាងយ៉ាប់មែនទែននឹង។

ក៖ កាលនឹងម៉េចដែរទៅអ៊ុំកាលនឹង?

ខ៖ កាលនឹងអ៊ុំចេះតែទៅធ្វើការងារទៅហើយដល់ពេលដែលបានយូរៗទៅអ៊ុំនឹងក៏បានចេះតែស្គាល់គេស្គាល់ឯងចឹងទៅក៏បានធ្វើការងារល្អទៅហើយពេលចឹងទៅបានអ៊ុំនឹងចេះតែសន្សំលុយទុកៗទៅពេលដែលរកបាននោះហើយចំណែកឯតាវិញគាត់ក៏រកបានមកដែលពេល

ដែលគាត់ចេញទៅធ្វើការងារអោយគេនៅតាមខេត្តនឹងចឹងទៅហើយបានចេះតែសន្សំតិចៗចឹងទៅហើយបានរាងធូចឹងទៅនោះកាលពីមុននឹងវាថារាងយ៉ាប់ៗណាស់តែម្តងនឹងម៉ង់តាមការពិតនឹងវាលំបាកតាមែនទែន។

កៈ ចាស!ចឹងផ្ទះនឹងអ៊ុំបានសន្សំលុយទុកធ្វើវាដែលចឹងក្នុងកំឡុងរយៈពេលប៉ុន្មានដែលអ៊ុំអាចសន្សំលុយដើម្បីធ្វើផ្ទះមួយនេះបាន?មើលទៅវារាងបានហើយអស់ចឹង?

ខៈ និយាយទៅផ្ទះនេះអង្គការគាត់បានជួយទាំងអស់ដល់ហើយតែម្តង់នឹងទាំងប៉ឹងឬស្សីហើយក្តារអីហើយវាមានប៉ឹងឬស្សីអីនៅលើដំបូលនោះវាជាប៉ឹងឬស្សីរបស់ផ្ទះយើងចាស់ ហើយគេបានយកប៉ឹងឬស្សីដែលចាស់នឹងទៅវៃដាក់ជាជញ្ជាំងអីចឹងវិញទៅណា ហើយសសរ មានទាំងនណ្ឌតហើយដែលវាមើលទៅរាងចាស់នឹងគេបានដាក់វាតគ្នាហើយមើលទៅវារាងមាំអីចឹងទៅណា បាននៅវាមាំតិចចឹងទៅ។

កៈ ចាស!

ខៈ ហើយចឹងទៅបានជាមានកូនវាបាននៅជុំគ្នាចឹងដែលទៅ។

កៈ ហើយផ្ទះនឹងចឹងកាលនឹងអង្គការគាត់ជាអ្នកជួយយើងតែទៅលើសំភារៈរឺងចំណែកងថ្លៃឈ្នួលអីយើងជាអ្នកដែលជួលខ្លួនឯង?

ខៈ កាលនឹងអង្គការនឹងគេបានជួយយើងមួយចប់តែម្តងទាំងការជួយយើងជួលជាងធ្វើផ្ទះអីមួយចប់តែម្តង គ្រាន់តែពេលដេលជាងនឹងគេមកចឹងទៅយើងនឹងមានកំលាំងច្រើនចឹងយើងក៏បានជួយជាងនឹងធ្វើជាមួយគ្នាមួយដៃមួយជើងចឹងទៅដើម្បីអោយវាឆាប់រួចទៅទាំងអស់គ្នាចឹងទៅ ចឹងទៅណាពេលខ្លះជាងនឹងវាមានគ្នាតិចមានតែ២នាក់អីចឹងទៅចឹងក៏យើងនឹងមានគ្នាច្រើនយើងក៏បានជួយគ្នាចឹងទៅ។

កៈចាស!

ខៈ យើងជួយគ្នាម្នាក់មួយដៃមួយជើងចឹងទៅព្រោះវាឆាប់បានស្នាក់នៅចឹងទៅកាលនឹងនោះ។

កៈ ចាស!

ខ៖ ហើយទៅកាលនឹងអង្គការអីនឹងគេបានជួយយើងទាំងជាងអីនឹងគេបានម៉ៅមួយចប់តែម្ដង។

ក៖ ចាស!ហើយសព្វថ្ងៃនឹងអ៊ុំមានមុខរបរជាងអ្វីដែលទៅអ៊ុំ?

ខ៖ សព្វថ្ងៃនឹងអ៊ុំនៅផ្ទះហើយអ៊ុំក្រង់ជាកន្ត្រក់អីចឹងទៅគ្រាន់បានមួយហូបៗអីចឹងទៅ។

ក៖ ចាស!អ៊ុំក្រង់ជាកន្ត្រក់លក់ន់អ៊ុំ?

ខ៖ ចាស!

ក៖ ហើយចឹងកន្ត្រក់នឹងលក់បានតំលៃប៉ុន្មានដែរ?

ខ៖ អត់បានដឹងដែលម្ចាស់គេនោះយើងស៊ីឈ្នួលតពីគេមកទេយើងដឹងតែធ្វើអោយគេហើយចឹងបានថាយើងនឹងធ្វើនឹងគេបានអោយក្នុងការធ្វើបានកន្ត្រក់មួយនឹងតំលៃ១០០០រហើយមានតួដែកអីនឹងស្រាប់សំរាប់អោយយើង....

ក៖ ចាស!

ខ៖ ហើយយើងនឹងដឹងតែចាក់ហើយក្រង់អោយគេទៅ...

ក៖ ចាស!

ខ៖ យើងក្រង់នឹងដាក់ក្រង់កន្ត្រក់ចំនួន៣ក្នុង១សែតហើយក្នុង១សែតនឹងគេអោយធ្វើមាន៣កន្ត្រក់ហើយ៣នឹងមានតូចមានមធ្យមហើយនឹងធំយើងដឹងតែ៣នឹងយើងបាន៣០០០រពេលដែលយើងនឹងធ្វើហើយ។

ក៖ ចាស!

ខ៖ ចឹងទៅ

ក៖ ហើយក្នុងមួយថ្ងៃចឹងតើអ៊ុំអាចធ្វើបានប៉ុន្មានដែរ?

ខ៖ ជូនកាលទៅអ៊ុំអាចធ្វើបាន៣ឈុតឬ៣សែតចឹងទៅបាន៩០០០រចឹងទៅហើយពេលខ្លះនឹងបានលឿនចឹងទៅក៏បានជាង១០០០០រចឹងទៅចឹងទៅណាបាន១៥០០០រហើយដោយថ្ងៃណាយើងអស់កំលាំងចឹងទៅយើងធ្វើបានត្រឹមតែប៉ុណ្ណឹងទៅ។

ក៖ចាស!

ខ៖ ហើយថ្ងៃណាយើងមិនសូវជាអស់កំលាំងយើងអាចរកបាន៤ទៅ៥ឈុតចឹងទៅហើយពេលណាដែលចៅវាមិនសូវជារករឿងចឹងទៅយើងក៏រកបានច្រើនតាមនឹងដែលទៅ។

ក៖ ហឺ!

ខ៖ ចឹងទៅ

ក៖ ចាស!ចឹងក្នុងមួយថ្ងៃអាចបាន១៥០០០រ?

ខ៖ ចាស!ចឹងទៅគ្រាន់អាចរួចបានទិញម្ហូបហើយសល់ខ្លះអោយចៅទៅរៀនចឹងទៅ។

ក៖ អូ ចឹងចំណែកឯសំភារ:អីនឹងគាត់មានអោយយើងទាំងអស់យើងមានតែកំលាំងធ្វើ?

ខ៖ ចាសនឹងហើយគេអោយសំភារ: យើងទាំងអស់នឹងយើងមានតែកំលាំងដើម្បីធ្វើកន្ត្រក់នឹងអោយគេនោះទេពេលធ្វើហើយចឹងគេនឹងមកយកខ្លួនឯងឬយកដាក់តុកតុកអោយគេទៅ។

ក៖ ចាស! ហើយចឹងការធ្វើនឹងគេជាអ្នកបង្រៀនអ៊ុំឬក៏ចេះខ្លួនឯងមក?

ខ៖ កាលនឹងអ៊ុំនឹងទៅអង្គុយទៅផ្ទះគេដែលគេបានធ្វើមុនខ្ញុំនឹងទៅមើលគេធ្វើថាគេយ៉ាងម៉េចចឹងហើយគេក៏រៀនធ្វើទៅក៏ចេះនឹងពេលដែលអ៊ុំនឹងជួយគេបានបន្តិចបន្តួចអីនឹងក៏ចេះចាក់ទៅហើយមើលគេចាក់ឡើងលើចុះក្រោមអីចឹងទៅយើងនឹងក៏ចាក់តាមគេនឹងយើងក៏ចេះទៅវាចឹង។

ក៖ ចឹងអ៊ុំឆាប់ចាប់បានដែលនឹង។

ខ៖ ចាស!

ក៖ ហើយស្អាតទៀត។

ខ៖ និយាយទៅអានេះនឹងដូចថាវាមិនពិបាកអីនឹងយល់ទេណានេះនឹងណាគ្រាន់ថាយើងនឹងមើលក្រឡាវាហើយចាក់ឡើងលើចុះក្រោមតាមក្រឡាវាចឹងទៅវាហើយៗមិនពិបាកអីទេវាមិនពិបាករៀននោះទេហើយដៃយើងនឹងយើងរុំវាទៅ។

ក៖ ហើយវាមានតែម៉ូតតែមួយនឹងទេអ៊ុំហ៎?

ខ៖ វាមានម៉ូតមួយទៀតអាមួយទៀតនឹងគេហៅវាថាម៉ូតភ្លោះព្រោះវាមានដៃភ្លោះ អានេះដៃវាមានតែមួយហើយអាមួយទៀតនឹងដៃវាមានរាងតូចជាងនេះបន្តិចមិនថាពិបាកក៏ថាបានហើយអាដៃភ្លោះនឹងវារាងពិបាកធ្វើជាងអានេះក៏ថាបានដែលព្រោះយើងត្រូវប្រើខ្សែច្រើនជាង។

ក៖ ហើយចំពោះតំលៃវាគេគិតអោយអ៊ុំប៉ុន្មានដែរ?

ខ៖ អាភ្លោះនឹងវាមាន១៥០០រក្នុង១កន្ទ្រក់។

ក៖ អូវារាងបានថ្លៃជាង។

ខ៖ នឹងហើយតែគ្រាន់ថាវាចំណាយពេលយូរជាងបើយើងធ្វើអានេះនេងយើងធ្វើបានចំនួនច្រើនជាងអាដៃភ្លោះនឹងព្រោះអីអាដៃភ្លោះនឹងវាយូរនឹងដៃវានឹងព្រោះដៃវាឡើងចឹងចេសមួយៗហើយនៅពទ័អាខាងឆ្នូតនេះទៀតនៅអូសនៅចំកណ្តាលទៀតចឹងហើយវារាងនៅយូរតែបើអានេះវិញយើងគ្រាន់តែចាក់ហើយរុំអានេះតិចៗហើយទៅបានហើយចំណែកឯនោះនឹងវារាងយូរណាស់ ប៉ុន្មានយើងនៅតែធ្វើចឹងទោះលំបាកអីចឹងក៏យើងនៅតែទ្រាំទៅទោះលំបាកអីនឹងយើងចេះតែធ្វើទៅព្រោះបើយើងទៅដើរសុំគេក៏គេមិនបានទៅអោយយើងនឹងហូបដែល។

ក៖ ត្រូវហើយអ៊ុំហើយមួយទៀតពេលដែលអ៊ុំធ្វើនេះអ៊ុំមានជំនាញទៀតដ៏ចឹងទៅអ៊ុំអាចធ្វើបានចឹងទៅពេលដែលអ៊ុំនៅថ្ងៃក្រោយទៅអ៊ុំអាចរកស៊ីបានខ្លួនឯងបានហើយមើលទៅនោះចឹងតើអ៊ុំមានគំរោងអីទេអ៊ុំនៅថ្ងៃមុខទៀត?

ខ៖ អ៊ុំមើលទៅនៅពេលដែលគេបានធ្វើផ្លូវអីអោយតែហើយទៅគេជីកឡូអីអោយវាហើយនឹងដាច់ស្រាច់អីអោយហើយទៅហើយអ៊ុំចង់ធ្វើជាអ្នកលក់បាយបបរអីចឹងទៅណាគ្រាន់បាននៅទៅហើយសល់អីទៅទុកគ្រាន់បានកូនចៅអីវាហូបបានមួយថ្ងៃៗដែរចឹងទៅណាគ្រាន់ជាង

យើងនៅតែផ្ទះនឹងវាអត់ប្រយោជន៍ដែលនឹងពេលដែលយើងនឹងធ្វើការងារទៅធ្វើអោយយើងនឹងវាមិនសូវជាឈឺដែលព្រោះយើងបានបញ្ចេញកំលាំង។

កៈចាស!

ខៈ ហើយចំណែកឯនៅតែផ្ទះអីយើងមិនបានធ្វើអីនឹងយើងវាចេះតែឈឺចឹង។

កៈ ចាស!

ខៈ ចឹងហើយបានជាអ៊ុំនឹងមិនចេះនៅទំនេរទេអ៊ុំចេះតែធ្វើនេះធ្វើនោះចឹងទៅហើយវាធ្វើអោយសរសៃររបស់យើងនឹងវារាងឡើងធូដែលចឹងទៅធ្វើអោយយើងនឹងវាមិនសូវជាឈឺព្រោះយើងបានដូចជាហាត់ប្រាណដែលនឹង។

កៈ ចាស!ចឹងសព្វថ្ងៃនឹងអ៊ុំមានឈឺអីទេអ៊ុំ?

ខៈ ខ្ញុំសព្វថ្ងៃនឹងមានឈឺដែលតែមានឈឺតែជំងឺតិចតួចទេដូចជាផ្ដាសាយអីនឹងប៉ុន្តែជំងឺខ្ញុំដែលសំខាន់នឹងមានតែបញ្ហាខាងក្រពះនឹងបេះដូងតែប៉ុណ្ណឹងនោះទេមានតែប៉ុនឹងវាចេះតែសុខសប្បាយដែលដល់ពេលណាដែលវាធ្វើទុក្ខអីចឹងទៅវារាងឡើងធ្វើទុក្ខរាងចុក ល្វលច្អលចឹងដែលចេញទឹកមាត់អីចឹងទៅហើយចុកមូលច្អលចេញទឹកមាត់អីចឹងទៅហើយក៏បាត់ទៅ។ ចំណែកអីបេះដូងវិញនឹងពេលដែលវាធ្វើទុក្ខអីនឹងវាបានសុខសប្បាយដែលវាមិនអីវាមិនបានធ្វើទុក្ខអីដូចគេចឹងទៅណា។

កៈ ចាស!ចឹងជំងឺនឹងយើងមិនអាចនឹងដឹងមុនបានទេថាវានឹងធ្វើទុក្ខក្នុងពេលណាមួយនោះ។

ខៈ ចាស!

កៈ ចាស!ហើយចឹងអ៊ុំនៅក្នុងគ្រួសារអ៊ុំមានសមាជិកគ្រួសារទាំងអស់គ្នាចឹងមានន័យថាសព្វថ្ងៃនឹងអ៊ុំនៅជាមួយនឹងគ្រួសារកូនអ៊ុំទាំងអស់ចឹងខ្ញុំបានលឺថាអ៊ុំមានបានរៀបអាពាហ៍ពិពាហ៍កូនរបស់អ៊ុំខ្លះនឹងពួកគាត់នៅជាមួយនឹងអ៊ុំដែរ?

ខៈ ចាស!គឺនៅជុំគ្នាទាំងអស់នឹងទាំង៨នាក់នឹងគឺនៅជាមួយគ្នាទាំងអស់តែម្តងនឹង។

កៈ ចឹងខ្ញុំសូមសួរបន្តថាតើគាត់ទាំង៨នាក់នឹងពួកគាត់មានមុខរបរជាអ្វីដែលអ៊ុំ?

ខ៖ មីងអូននេះវានៅផ្ទះហើយកូន ហើយចំណែកឯនោះវិញនឹងគេបានធ្វើការខាងផ្នែកក្រសួងអនាម័យអ្វីដែលគេអាចបានធ្វើជាអ្នកអនាម័យដែលពេលខ្លះចឹងទៅគាត់នឹងក៏បានទៅរើសសំរាមតាមឡានអនាម័យនឹងឯងហើយចឹងទៅគេបានទៅសំអាតចឹងទៅណាតែឥឡូវនឹងវាមានផ្ទៃពោះចឹងទៅគេនឹងក៏បានអោយយើងនឹងឈប់សំរាកខ្លះចឹងទៅណាចំណែកឯប្តីនឹងវាបានទៅជួយលៀងម៉ាស៊ីនត្រជាក់អីចឹងទៅគ្រាន់បាន១ចាយៗអីចឹងទៅការងារគេនឹងត្រូវជាមួយនឹងម៉ាស៊ីនត្រជាក់នឹងចឹងទៅ។

ក៖ ចាស!ល្អមែនទែនដែលពួកគាត់ចេះតស៊ូខិតខំធ្វើការ...

ខ៖ ចាស!

ក៖ ចាស!ចឹងហើយអ៊ុំគិតថានឹងមានគំរោងអីសំរាប់ពួកគាត់ក្នុងការរស់នៅនឹងមានគំរោងអីដែលឬទេសំរាប់ពួកគាត់?

ខ៖ អ៊ុំមិនទាន់ដឹងទេរឿននឹងនោះព្រោះអានឹងវាអាស្រ័យទៅលើតាទេថាគាត់នឹងចង់ធ្វើយ៉ាងម៉េចព្រោះអីគាត់ជាអ្នកដែលដឹងច្រើនជាអ៊ុំព្រោះវាអាស្រ័យថាពេលដែលតានឹងគាត់ដើរទៅមើលដីគេចឹងទៅយើងនឹងអាចនឹងរកបានដីគេអី១កន្លែងអីចឹងទៅយើងក៏នឹងគិតគូរថាត្រូវសង់ផ្ទះឬធ្វើអីសំរាប់ពួកកូនៗនឹងដែរ ហើយចឹងពេលបានដីហើយនឹងយើងនឹងអាចអោយពួកគេទៅបែកទៅនៅកន្លែងណាបាន១កន្លែងដែលចឹងទៅប៉ុន្តែឥឡូវនឹងយើងមិនទាន់បានដឹងនៅឡើយទេរឿងនឹងនោះ។

ក៖ ចាស!

ខ៖ វានៅមានរឿនស្មុកស្មាញច្រើនទៀតណា។

ក៖ ចាស!

ខ៖ នឹងហើយ

ក៖ ចាស!ចឹងតាមរយៈនឹងធំមានបទពិសោធន៍រឿងជីវិតច្រើនដែលអ៊ុំធ្លាប់បានឆ្លងកាត់មករហូតកាលតាំងពីអ៊ុំនៅពីក្មេងនឹងរហូតដល់អ៊ុំមានអាយុបានប៉ុណ្ណឹងណាអ៊ុំ។

ខ៖ ចាស!

ក៖ ចាសចឹងខ្ញុំសូមសួរអ៊ុំថាតើអ៊ុំមានបទពិសោធន៍ជីវិតអ្វីគេដែលធ្វើអោយអ៊ុំនឹកចាំរហូតមកដល់សព្វថ្ងៃនឹងដែលវាធ្វើអោយអ៊ុំនឹកចាំមិនភ្លេចសោះណាអ៊ុំដែលវាបានធ្វើអោយអ៊ុំពិបាកនឹងចង់ចាំមិនភ្លេចសោះឡើយណាអ៊ុំ?

ខ៖ ចាស! ការលំបាកដែលអ៊ុំចង់ចាំមិនភ្លេចឡើយនឹងមានតែនៅក្នុងជំនាន់អាពតដែលវាបានធ្វើអោយយើងនឹងបានបែកបាក់បងប្អូនយើងហើយនឹងឪពុកម្ដាយយើងនឹងវាពិបាកដែលអ៊ុំចង់ចាំមិនបានភ្លេចហើយកាលនឹងអ៊ុំមានតែ២នាក់បងនឹងប្អូននឹងវាធ្វើអោយយើងនឹងជាក្មេងកំព្រាចឹងទៅណាហើយយើង២នាក់នឹងបានកាន់ដៃគ្នាមកពីជំនាន់ដាច់អាពតនឹងចឹងទៅណាហើយមានការចង់ចាំនឹងខ្លាំងជាងគេនឹងអ៊ុំចង់ចាំខ្លាំងជាងគេនឹងគឺកាលនៅនិងជំនាន់អាពតនឹងតែម្ដងនឹង។

ក៖ ចាស!អ៊ុំ ហើយពេលនឹងគេបានជំលៀសអ៊ុំទៅណាដែល?

ខ៖ កាលនឹងគេបានជំលៀសអ៊ុំទៅឆ្ងាយណាស់ប៉ុន្តែបើយើងនឹងចង់នៅជិតក៏បានដែលតែបើយើងនឹងចង់វាមិនចឹងនៅជិតៗនឹងយើងចេះតែទៅឆ្ងាយៗទៅព្រោះតែកាលដែលនៅជិតៗបើគេបានដឹងជីវៈប្រវត្តិរបស់យើងកាលនៅពីសង្គមនឹងចឹងគេនឹងវៃយើងនឹងចោលលីបានទេ?

ក៖ ចាស!

ខ៖ ដល់ហើយចឹងទៅចេះតែទៅចេះតែទៅផុតៗយើងពីស្រុកទេសភូមិកំណើតរបស់យើងចឹងទៅពីម្ដាយឪពុកយើងចឹងទៅកាលនឹងនោះ ចេះតែបានទៅៗឯឆ្ងាយៗចឹងទៅហើយពេលនឹងគាត់បានឈឺកើតជាជំងឺហើមមុខជើងដៃអីនឹងចឹងទៅហើយក៏ពួកគាត់បានស្លាប់ទៅនិយាយទោនៅក្នុង១ឆ្នាំនឹងពួកគាត់បានស្លាប់តៗគ្នាគ្រួសាររបស់ខ្ញុំនឹងមានម្ដាយឪពុកបងប្អូនម្ដាយធំអីនឹងចឹងទៅគឺពួកគាត់បានស្លាប់តៗគ្នានៅក្នុង១ឆ្នាំនឹងស្លាប់តៗគ្នាទៅបាត់អស់ទៅនៅពេលដែលវៀតណាគេជិតមកចូលរំដោះនឹងស្រាប់តែឪពុករបស់ខ្ញុំនឹងគាត់បានស្លាប់នៅក្នុងផ្ទះនឹងបាត់ចឹងទៅ ពេលដែលទ័ពវៀតណាមគេបានចូលមកដល់នឹងគេបានប្រាប់អ៊ុំថាផ្ទះរបស់ឯងនឹងដែលមានឪពុកឯងនឹងនៅក្នុងនឹងគេបានដុតបូជាគាត់នៅក្នុងផ្ទះនឹងអោយហើយព្រោះគាត់បានស្លាប់បាត់ទៅហើយ ហើយពេលនឹងគាត់ស្លាប់នៅលើផ្ទះនឹងកាលនឹងខ្ញុំនៅតូចៗ

ដែលចឹងទៅមិនបានដឹងពីរបៀបនឹងមិនអាចយកគាត់ទៅកប់ឯណាកើតទេកាលនឹងនោះ បានតែឈរមើលហើយកាលនឹងទ័ពវៀតណាមនឹងគេបានចូលមកហើយនឹងពេលនឹងយើងនឹងកំពុងតែជ្រួលជ្របល់ហើយនឹងដល់ហើយចឹងអាពតវាថាអាណាមិនចេញទេវានឹងបាញ់អោយងាប់ជាមួយនឹងគ្រួសារចឹងទៅ ដល់លឺគេថាចឹងខ្ញុំនឹងក៏បានដើរចេញទៅតាមគេហើយក៏បានចេញពីផ្ទះពីភូមិនឹងទៅបាត់ទៅវាចឹងឯងកាលនឹងនោះ។

ក៖ កាលនឹងគាត់មានទីលំនៅនៅក្នុងភូមិឃុំណាដែល?

ខ៖ កាលនឹងគាត់មានទីលំនៅនៅក្នុងភូមិគួបឃាមមួយនៅក្នុងស្រុកអីដែលទេកាលនឹងនោះព្រោះអីកាលនឹងអ៊ុំបានស្គាល់តែភូមិយើងនៅនឹងគឺមានឈ្មោះថាភូមិគួបឃាម ចាស។

ក៖ ហើយគេពេលនឹងបានធ្វើអ្វីខ្លះដែលពេលដែលអាពតបានចូលមកហេតុអ្វីបានជាឪពុករបស់អ៊ុំនឹងស្លាប់តើគាត់បានស្លាប់ដោយសារតែជំងឺឬក៏ដោយមូលហេតុអ្វីផ្សេង?

ខ៖ កាលនឹងគាត់បានស្លាប់ដោយសារតែជំងឺព្រោះកាលនឹងគាត់បានដូចជាចាញ់ទឹកចាញ់ដីដែលជាកន្លែងថ្មីដែលពួកគាត់នឹងទៅនៅនឹងហើយបានដូចជាគាត់ហូបវាមិនដូចជាកាលគាត់នៅក្នុងជំនាន់សង្គមអីចឹងទៅបានជាគាត់នឹងធ្លាក់ខ្លួនឈឺនឹងព្រោះកាលនឹងចូលជំនាន់អាពតនឹងគាត់ចេះតែហូបអីបានតែត្រពីត្រពៀសនោះនឹងហើយចឹងទោបានជាគាត់ឡើងរោគនឹងជាខ្លួនមានពណ៌សំបរវាងពណ៌លឿន ហើយខ្លួននឹងវារាងក្ដៅខ្លួនខ្លាំងនឹងឡើងរងារញាក់ចឹងទៅណាពួកគាត់បានស្លាប់ចឹងកាលនឹងបងប្អូនរបស់ខ្ញុំនោះកាលនឹងនោះ។

ក៖ ចាស!ហើយកាលពីមុននឹងតើបងប្អូនក្រុមគ្រួសាររបស់អ៊ុំនឹងតើពួកគាត់ទាំងអស់គ្នាកាលនឹងតើពួកគាត់មានមុខរបរជាអ្វីដែលឬកាលនឹងគាត់មានការងារអ្វីខ្លះដែរអ៊ុំ?

ខ៖ កាលនឹងឪពុកខ្ញុំនឹងគាត់ធ្វើការងាររបស់គាត់នឹងដូចជាអ្នកយាមប៉ុសន៏អីនោះក្នុងស្រុកភូមិអីចឹងទៅណាកាលនឹងនោះលើមុននឹងគាត់បាននៅក្នុងភូមិគីឡូលេង៩ផ្លូវមន្ទីពេទ្យលោកសង្ឃយើងនឹង នៅនឹងនៅម្ដុំនឹងទេកាលនឹងនោះគេអោយគាត់នឹងនៅនឹងដើម្បីនឹងទៅយាមប៉ុសន៏នឹងអ្នកភូមិនៅនឹងចឹងទៅណាហើយពេលដែលយប់ឡើងអីនឹងគាត់បានអោយគ្នានឹងគាត់ផ្លាល់នឹងទៅដើរមើលផ្ទះអ្នកភូមិអីចឹងតិចចឹងទៅណាកាលនឹងនោះគាត់ធ្វើការងារចឹងទេ

ហើយកាលនឹងចំណែកឯម្តាយរបស់ខ្ញុំវិញនឹងគាត់ជាអ្នកលក់ដូរបន្លែនៅតាមភូមិនឹងដែលនឹង។

កៈ ហឺ! ចាសហើយក្រោយពេលបានចូលនៅក្នុងជំនាន់អាពតនឹងគេបានជំលៀសអោយគាត់បានទៅធ្វើអ្វីខ្លះដែលអ៊ុំកាលនឹង?

ខៈ កាលនឹងគេបានអោយគាត់ទៅធ្វើជីលាមកយើងនឹងទៅលាយចូលគ្នាដើម្បីធ្វើជាជីអីចឹងទៅចំពោះប្រុសៗយើងនឹងនោះហើយគេបានទុកអោយស្រីៗយកទៅរែកចាក់តាមស្រែអីចឹងទៅកាលនឹងវាចឹងឯង។

កៈ ចឹង!កាលនឹងគេបានយកលាមករបស់មនុស្សនឹងយកទៅធ្វើជាជីសំរាប់ដាក់តាមស្រែដែរ?

ខៈ នឹងហើយគេយកទៅដាក់ហើយពេលខ្លះទៅគេក៏បានយកលាមកគោអីចឹងដែលទៅដើម្បីយកទៅដាក់ដែលចឹងទៅណានឹងវាចឹងឯងហើយមានស្លឹកក្រដៀងខែតគេអោយយើងយកមកកាប់ជញ្ជាំងហើយដាក់លាយគ្នាទៅហើយយើងយកទៅដាក់នៅតាមរន្ធដៅដែលគេកាប់សំរាប់ទុកនៅក្នុងនឹងរួចជាស្រោចវាចឹងឯងកាលនឹងនោះ។

កៈ ចាស!ចឹងកាលនឹងវាស្អុយខ្លាំងហើយព្រោះគេបានយកជីលាមកទៅដាក់នៅតាមស្រែចឹងនោះ?

ខៈ អា!នឹងវាចឹងហើយតែយើងទៅធ្វើយ៉ាងម៉េចបើកាលនឹងគេអោយយើងទៅយើងត្រូវតែទៅហើយព្រោះមិនចឹងទេគេនឹងយកយើងនឹងទៅសំលាប់ចោលជាមិនខានទេព្រោះគេនឹងវានៅលើយើងតែថាយើងនឹងធ្វើខុសអីហើយមិនស្តាប់គេនឹងគេមិនបានទៅទុកយើងអោយរស់នៅនោះទេ។

កៈ ចុះ!រន្ធដៅនឹងគេបានជីរាងយ៉ាងម៉េចដែរ?

ខៈ កាលនឹងគេជីសំរាប់ដាក់ស្លឹងកន្ត្រៀងខែតហើយគេបានដាក់លាមកនឹងអាចម៍គោអិចឹងទៅដាក់ចូលគ្នាអោយវាមើលទៅរាងរលួយហើយនឹងគេក៏អោយយើងនឹងទៅដួសវាចេញមកហើយរែកចូលទៅក្នុងស្រែចឹងទៅកាលនឹងនោះ។

កៈ អូ!

ខ៖ ហើយគេបានដាក់វាលាយគ្នាចឹងទៅហើយចំណែកឯស្រីៗវិញគេអោយយើងនឹងទៅបោចស្មៅអីចឹងទៅដែលមានទីតាំងនៅតាមចំការឬតាមកន្លែងដែលគេអោយយើងនឹងទៅបោចវានឹងចឹងទៅ ហើយចំណែកឯប្រុសៗវិញគេនឹងក៏បានអោយយើងនឹងទៅកាប់គុលវានឹងសំអាតកន្លែងអីចឹងដែលទៅស្រីកងនារីដែលពេញវ័យដែលជានារីមានកំលាំងអីនឹងគេអោយទៅរែកដីដែលចឹងទៅជាមួយនឹងកងប្រុសៗដែលតែគេអោយដើរបំបែកគ្នាកងស្រីៗនឹងដើរមួយជួរៗនឹងចំណែកឯកងប្រុសៗនឹងគេក៏អោយយើងដើរ១ជួរដែលចឹងដែលទៅហើយពេលខ្លះទៅនឹងគេក៏អោយយើងនឹងទៅជីបន្លាយអីចឹងដែលទៅអានឹងវាចឹង។

ក៖ ចាស!ហើយកាលនឹងគេបានប្រើអ៊ុំអោយធ្វើការងារអ្វីខ្លះដែលទៅអ៊ុំ?

ខ៖ កាលនឹងគេបានប្រើអ៊ុំនឹងអោយធ្វើការងាររែកទឹកអោយទៅចុងភៅគេព្រោះអីកាលនឹងយើងនឹងវានៅតូចដែលចឹងហើយគេអោយតែរែកទឹកនឹងសំរាប់អោយចុងភៅគេនឹងដាក់ដាំបាយស៊ីនឹងហើយក៏តែយើងនឹងនៅក្នុងវ័យកុមារដែលគេថាគេអោយតែកងកុមារនឹងធ្វើការអីដែលស្រាលៗនោះទេគេមិនហ៊ានអោយយើងនឹងធ្វើការងារណាដែលរាងធ្ងន់ៗនោះទេវាចឹងឯងនឹងដល់នេះចឹងទៅគេនឹងក៏អោយអ៊ុំនឹងទៅឯកងកុមារដែលគេនឹងបានអោយទៅធ្វើការងារនៅឯកន្លែងផ្សេងៗខ្លះដែលពេលនឹងគេថាជាកងកុមារចាលាតវាលំបាកដែលកាលនឹងនោះព្រោះអីកាលនឹងយើងនៅក្មេងៗហើយកុមារវានៅតូចចំណែកឯកងកុមារផ្សេងៗទៀតនឹងគេបានរើសគ្នាណាដែលមានរាងធំៗនឹងទៅហើយនៅសល់តែយើងចឹងដំពេលចឹងមានកងកុមារដែលមានគ្នាចំនួនបាន៩នាកអីចឹងហើយខ្វះម្នាក់ចឹងទៀតនឹងគេក៏រើសយើងចូលទៅដែលទៅកាលនឹងហើយគេនឹងសុទ្ធតែប្រុសៗហើយគេនឹងមានកំលាំងនឹងធំជាងអ៊ុំចឹងហើយយើងកាលនឹងគេមិនសូវអោយអ៊ុំនឹងធ្វើអីដែលទេកាលនឹងនោះព្រោះគេធំចឹងគេបានទៅជំរះកន្លែងហើយគេបានទៅកាប់ព្រៃជំរះអីនឹងអស់ៗនឹង។

ក៖ ហើយកាលនឹងអ៊ុំបានចាំទេថាកាលនឹងអ៊ុំមានអាយុប៉ុន្មានដែល?

ខ៖ កាលនឹងអ៊ុំមានអាយុក្រោម១០ឆ្នាំអីតិចតួចប៉ុន្តែខ្ញុំចេះដឹងក្តីហើយចេះចាំអីចឹងកាលនឹងទំរង់នឹងប៉ុន្តែកាលនឹងខ្ញុំនឹងមានអាយុក្រោម១០ឆ្នាំមែនពិតតែខ្ញុំបានចាំកាលនឹង។

ក៖ ចាស!

ខ៖ កាលនឹងខ្ញុំចេះចាំនឹងដូចមនុស្សចាស់ចឹងកាលនឹងនោះខ្ញុំបានចេះចាំនឹងកាលនឹងនោះ។

ក៖ ហើយចឹងកាលនឹងអ៊ុំចេះចាំអីខ្លះដែលកាលនឹងអ៊ុំ?

ខ៖ កាលនឹងខ្ញុំថាយើងនឹងបានដើរធ្វើជាកងកុមារចឹងទៅជាមួយនឹងកងនារីគេដែលមានរាងក្រមុំៗនឹងចឹងទៅបាន១រយៈចឹងទៅហើយកាលនឹងកងកុមារនឹងអ៊ុំបានដាំអីដាំអីជាមួយនឹងគេជាមួយនឹងកុមារអីចឹងទៅកាលនឹងវាចឹង។

ក៖ ចុះកាលនឹងអ៊ុំជាកងកុមារមែនទេអ៊ុំ?

ខ៖ ចាស!កាលនឹងអ៊ុំជាកងកុមារហើយដល់ពេលចឹងទៅអ៊ុំនឹងបានដឹងថាកាលនឹងអ៊ុំនឹងមានម៉ែៗដែលមើលយើងនឹងនៅក្នុងកងកុមារនឹងថាអ៊ុំនឹងឧស្សាហ៍ចឹងទៅគាត់ក៏អោយអ៊ុំមកជួយដងទឹកមានចំនួន២នាក់អោយទៅជួយគាត់នឹងមានខ្ញុំនឹងម្នាក់ទៀតអោយទៅជួយហើយគាត់អោយមកដងទឹកសំរាប់ ពួកគាត់ដាំបាយចឹងទៅកាលនឹងនោះយកទៅអោយចុងភៅនឹងម៉ែៗនឹងចុងភៅមូលដ្ឋាននឹងចឹងទៅកាលនឹងវាចឹង។

ក៖ ហឺ!.

ខ៖ ហើយកាលនឹងយើងនឹងក៏ទៅប៉ះបន្លែអីសំរាប់អោយម៉ែៗនឹងយកមកដាំស្លអីចឹងដែលទៅកាលនឹងវាចឹងហើយបានទៅយកអីសំរាប់ឪពុកម្តាយខ្ញុំចឹងទៅ។

ក៖ អូចឹងកាលនឹងអ៊ុំក៏មានសិទ្ធិនៅក្នុងការយកបន្លែអីមកអោយម្តាយសំរាប់ដាំស្លអីចឹងដែល?

ខ៖ និយាយទៅភូមិខ្ញុំនឹងវាស្រួល...

ក៖ អូចឹង....!

ខ៖ ខ្ញុំបានជួបភូមិខ្ញុំនឹងវារាងស្រួលដូចព្រោះអីកាលនឹងពេលដែលមានបន្លែអីនឹងសំរាប់ធ្វើជាម្ហូបនឹងខ្ញុំអាចយកទៅផ្ញើគាត់បានដោយយើងនឹងចេះមានពាក្យគួសមអីចឹងទៅដែលនឹងគេមិនទៅចិត្តអាក្រក់នឹងយើងនោះទេយើងប្រាប់គេអោយថាម៉ែៗអោយកូនសុំស្ពីបន្តិចមកម៉ែចឹងទៅណាហើយចឹងទៅគេក៏អោយមកយើងបន្តិចមកហើយយើងកុំអោយលួចគេយើងចង់បានអីប្រាប់គេទៅគេអោយយើងហើយអោយតែយើងនឹងចេះប្រើពាក្យសុំគេទៅគេអោយយើង

ហើយកុំអោយតែយើងនឹងទៅលួចគេបើយើងនឹងទៅលួចគេតែម្តងទៅ២ដងនឹងតែគេបានដឹង គេនឹងយកយើងនឹងទៅវៃចោលហើយ ចឹងយើងត្រូវសុំទៅបើគេថាមិនអោយទេយើងក៏មកវិញ មកអានឹងវាចឹងឯង។

កៈ ចាស! គេអោយហើយចឹងអ៊ុំយកទៅផ្ទះចឹងបាន?

ខៈ ចឹងហើយគេអោយយើងយកទៅផ្ទះរបស់យើងបានពេលនឹងនោះចឹងទៅកាលនឹងណាអ៊ុំ នឹងពេលដែលទៅរែកទឹកក៏ចឹងដែលកាលនឹងនោះគេបានអោយអ៊ុំនឹងជាជំឡូងទៅខ្លះទៅក៏ជា របបជាបាយសំរាប់អោយយើងទៅហើយពេលខ្លះនឹងក៏គាត់បានអោយយើងនឹងជាមីអីចឹង ដែលទៅពេលខ្លះនឹងនោះ ប៉ុណ្ណឹង១ឯងខ្លះទៅវាមានប្រវែងរាងវែងដូចជាងនេះចឹងដែលទៅ កាលនឹងនោះវាមិនទៅពិបាករឿងហូបទេកាលដែលខ្ញុំនៅជាកងកុមារប៉ុន្មានវាមិនដូចពេល សម័យសង្គមចង់ញាំអីក៏បាននោះទេចឹងហើយបានថាកាលនឹងបើធៀបទៅខ្ញុំវាមានសំណាង ជាងក្មេង១ដែលរស់នៅក្នុងជំនាន់អាពតនឹងក៏ថាបានដែលពេលនឹងនោះព្រោះអីពេលនឹងខ្ញុំ មានរបបហូបបានច្រើនជាងគេតែពេលដែលគេបានអោយរបបអាហារអោយខ្ញុំនឹងខ្ញុំមិនបាន ហូបខ្លួនឯងទេកាលនឹងនោះព្រោះខ្ញុំត្រូវយករបបអាហារដែលត្រូវជារបស់ខ្ញុំនឹងទៅអោយ ឪពុកម្តាយរបស់ខ្ញុំដែលពួកគាត់នៅឯផ្ទះឯនោះចឹងហើយបានជាខ្ញុំនឹងមិនបានហូបរបបរបស់ ខ្លួនឯងនោះទេ ពេលនឹងគេបានអោយជំឡូរអោយខ្ញុំបាន១ដុំអីនឹងខ្ញុំយកទៅអោយគាត់ហើយ ព្រោះនឹកឃើញថាគាត់នឹងវាមានកំលាំងចាស់ចឹងហើយបានជាសុខចិត្តថាធ្វើយ៉ាងម៉េចអោយ គាត់បានឆ្អែកទៅព្រោះអីគាត់វាចាស់ជាងយើងគាត់តស៊ូទ្រាំគាត់ទ្រាំមិនបាននោះទេតែ ចំណែកឯយើងវិញក្មេងយើងអាចនឹងទ្រាំបានចឹង ខ្ញុំក៏សុខចិត្តយកអោយគាត់ហូបទៅខ្ញុំមើល គាត់ចឹងខ្ញុំក៏សុខចិត្តយកអោយគាត់ហើយគាត់ក៏បានហូបទៅកាលជំនាន់ពពតនឹងនោះ។

កៈ តើគាត់កាលនឹងគាត់មានអាយុប៉ុន្មានដែល?

ខៈ កាលជំនាន់នឹងគាត់ដូចជាមានអាយុ៥០ជាងហើយ។

កៈ ចឹង!កាលនឹងគាត់មានសភាពជាទ្រុឌទ្រោមហើយព្រោះដោយសារបាក់កំលាំង?

ខៈ ចាស!ព្រោះទឹមតែថ្មី១នឹងគាត់អត់អីទេហើយពេលដល់រាងយូរ១ទៅគាត់រាងដូចជាយ៉ាប់ ទៅព្រោះអីកាលនឹងនោះគេមិនសូវអោយគាត់បានហូបគ្រាប់គ្រាន់ដ៏ចឹងទៅគាត់នឹងចេះតែ

រាងហាត់ទៅចឹងហើយបានជាគាត់ឈឺហើយស្លាប់នោះអីកាលនឹងវាមិនសូវជានៅជំនាន់កាលសម្តេចព្រះបាទនរោត្តសីហានុដែលកាលនឹងយើងនឹងវាបានហូបគ្រាប់គ្រាន់ចឹងតែជំនាន់អាពតបានចូលមកនឹងធ្វើអោយយើងពិបាកនឹងរស់នឹងព្រោះគេដូចជាមិនសូវយើងនឹងបានហូបហើយគេប្រើយើងនឹងឡើងចង់អោយយើងនឹងស្លាប់តែម្តងនឹងគាត់ឡើងបាក់កំលាំងចឹងទៅហើយកាលនឹងគាត់នឹងហូបវាតាពាសមានហូបតាំងពីសំបកដំឡូងឈើនឹងគេបានអោយយើងនឹងកូសមកហើយធ្វើជ្រក់ក៏មានហើយចំណែកឯសំបកឪឡឹកវិញនឹងគេបានត្រាមហូបចឹងទៅហើយពេលនឹងផ្ទះមូលដ្ឋានគេនឹងគេបានចិតយកតែសាច់ហើយសំបកឪឡឹងនឹងគេចិតហើយនឹងគេក៏បានយកទៅបោះចោលទៅហើយយើងនឹងក៏បានយកវាមកចិតត្រាំមហូបពេលនឹងខ្លះទៅយកសំបកនឹងទៅចិតទ្រាំមទឹកអំបិលហើយញ៉ាំជាមួយបាយហើយហូបទៅពេលដែលវារាងឡើងរសជាតិរៀងជូរហើយនឹងចឹងយើងក៏យកវាមកដើម្បីហូបទៅអានឹងវាចឹងឯង។

ក៖ ចាស!ហើយចុះចំណែកឯបាយវិញតើយើងបានអង្ករពីណាមកសំរាប់ដាក់ដាំបាយ?

ខ៖ អូ!សំរាប់អង្ករនឹងគេចែកអោយយើងក្នុង១អាទិត្រម្តងគេចែកអោយជារបបអោយយើងចឹងទៅតែក្រោយមកនឹងគេក៏បានអោយយើងនឹងធ្វើបាយរួមជាមួយនឹងគេវិញម្តងដល់ម៉ោងបាយចឹងយើងត្រូវទៅហូបចឹងទៅ។

ក៖ ចាស!

ខ៖ ដល់ពេលព្រឹកឡើងចឹងទៅមុនចេញទៅធ្វើការនឹងគេបានចែកអោយពេលនឹងដល់ម៉ោងគេចេញពីធ្វើការគេបានដើរមករកបាយហូបចឹងគេត្រូវតំរង់ជូរគ្នាដើម្បីយកបាយរាងៗខ្លួនចឹងទៅពេលនឹងនោះពេលនឹងយើងបានតែបបរទេសំរាប់របបអាហារនោះតែដល់ពេលខែច្រូតយើងបានជារបបបាយស្រួយដែលគេអោយយើងនឹងហូបបានមួយសេរីភាពពេលនឹងនោះហើយពេលនឹងអ្នកដែលហូបបាយរាងច្រើនវាឆ្អែកហើយតែបើថាគេជាអ្នកដែលហូបបាយរាងតិចៗចឹងដឹងតែវានៅសល់តិចតួចចឹងដែលទៅណា។កាលនឹងគេបានចែកអោយយើងនឹង១ចានតូចនឹងហើយដល់ពេលខែស្នងនឹងគេមានជាបបរវាងមើលទៅខាប់វាឡើងខាប់ខ្លាំងមែនទែនពេលនឹងហើយគេបានដាក់លាយជាមួយនឹងដំឡូងមានតែមួយៗនោះទេកាលនឹងនោះ បើភូមិគេផ្សេងខ្ញុំបានលឺគេថាបើភូមិគេផ្សេងគេបបរឡើងមើលទៅរាវសុទ្ធតែម្តងរកមើលតែគ្រាប់អង្កមិនឃើញនោះទេកាលនឹងនោះតែបើភូមិខ្ញុំវិញនឹងមិនចឹងនោះទេភូមិនេះដែលខ្ញុំនៅនឹងមិនដែល

បានជួបប្រទះបញ្ហាចឹងនោះទេអ្នកភូមិខ្ញុំនឹងនោះហើយចំណែកឯសហាករមូលដ្ឋានអីកាលនឹងក៏មិនអីដែលវាមានសភាពស្ងាត់ស្រួលណាស់ដែលនឹងជាមួយនឹងអ្នកថ្មីយើងនឹងហើយដូចថាខ្វះខាតអីដែលយើងមានបងប្អូនយើងអីដែលពួកគាត់នឹងឈឺអីចឹងណាស់ដល់ពេលដែលយើងនឹងទៅសុំគេនឹងគេមើលឃើញចឹងគេក៏អោយយើងដែលកាលនឹងនោះវាចឹងឯងយើងបានយកអោយគាត់នឹងមកហូបព្រោះអីកាលនឹងពេលដែលឪពុកយើងចង់បាយជាមួយនឹងស្ករពាងចឹងយើងទៅសុំគេចឹងគេអោយម៉ែចុងភៅដូសអោយយើងដោយគេបានដូសដាក់នៅក្នុងត្រឡោតមកអោយយើងដែលកាលនឹងនោះ។នៅនុះដែលរាងស្រួលតែគ្រាន់ថាពេលដែលរាងទុក្ខលំបាកអីកាលនឹងវារៀងលំបាកហើយលំបាកខ្លាំងនឹងពេលដែលគាត់នឹងបានឈឺចឹងហើយគាត់បានស្លាប់ហើយគាត់បានបែកចេញពីយើងនឹងចឹងហើយវាធ្វើអោយយើងនឹងវាយ៉ាបលំបាកតែប៉ុណ្ណឹងនោះទេកាលនឹងនោះពេលដែលយើងនឹងពីភាពលំបាកចិត្តជាខ្លាំងព្រោះអីកាលនឹងយើងចង់អោយគាត់បាននៅជុំគ្នាជាមួយនឹងយើងដូចដែលគ្រួសារដែលគាត់នឹងកូនៗគេបានជួបជុំគ្នាក្រោយពីជំនាន់អាពតនឹងណាយើងឃើញគេចឹងយើងនឹងក៏ចង់អោយគាត់បាននៅជុំរុំគ្នាដូចជាក្រុមគ្រួសារគេផ្សេងៗទៀតដែលនឹងគ្រាន់តែចង់ចឹងប៉ុន្តែឥឡូវនឹងគាត់បានបែកបាក់ពីយើងទៅនឹងតាំងពីយើងនៅកាលពីតូចៗម្លេះហើយចឹងហើយក៏មានការសោកស្តាយអានឹងវាចឹងឯង។

ក៖ ចឹងកាលនឹងពេលដែលគាត់បានស្លាប់នឹងអ៊ុំបានមើលឃើញគាត់ស្លាប់ទៅនៅមុខអ៊ុំផ្ទាល់តែម្តង?

ខ៖ នឹងហើយកាលនឹងអ៊ុំបានដឹងទាំងអស់ហើយទាន់ពួកគាត់ស្លាប់ទាំងអស់នឹងកាលនឹងនោះព្រោះអីកាលនឹងខ្ញុំបានដើរទៅគ្រប់កន្លែងដែលពួកគាត់រស់នៅហើយមើលឃើញពួកគាត់ទាំងអស់គ្នានឹងកាលនឹងនោះខ្ញុំបានទាន់ដង្ហើមទាំងអស់តែម្តងហើយមួយផ្ទះខ្ញុំនឹងគេមានជំងឺហើមទាំងអស់នឹងចឹងហើយពេលនឹងអត់មានហើមតែខ្ញុំមួយនឹងទេកាលនឹងនោះហើយពេលនឹងខ្ញុំបានទាន់ការស្លាប់របស់ប្អូនប្រុសខ្ញុំទី៤ខ្ញុំបានទៅទាន់គេបានស្លាប់នៅនឹងមុខខ្ញុំតែម្តងនឹងទាន់គេស្លាប់ហើយពេលជិតវាស្លាប់នឹងម្តាយខ្ញុំនឹងក៏នៅជាមួយដែលប៉ុន្តែពេលនឹងម្តាយខ្ញុំនឹងគាត់រាងអស់កំលាំងចឹងហើយពេលនឹងគាត់ក៏បានសំរាកហើយបិទភ្នែកសំរានទៅចឹងហើយខ្ញុំនឹងជិតនឹងបានមើលឃើញប្អូនខ្ញុំនឹងដែលគេបានដេកនៅជិននឹងដែលនឹងបានចាប់ផ្តើមដងចង្កាមាន់(ដងខ្យល់រកស្លាប់) ហើយភ្លាមៗនឹងវាក៏ផុតដង្ហើមទៅហើយពេលនឹងខ្ញុំឃើញចឹងក៏បាន

ទៅជាសម្តាយរបស់ខ្ញុំថាម៉ែៗអាអូនវាលែងដង្ហើមអីចឹង?ហើយដល់ពេលចឹងម្តាយខ្ញុំក៏បានមក មើលហើយគាតបានប្រាប់ខ្ញុំថាអាអូននឹងគាត់បានស្លាប់បាត់ហើយកាលនឹងនោះ។

ក៖ ហ៊ើស!

ខ៖ ពេលនឹងខ្ញុំបានលឺវាកំពុងតែដកចង្ការដល់ចឹងទៅប្អូនខ្ញុំនឹងគេបានស្លាប់ទៅហើយនឹងមក ម្តាយធំខ្ញុំទៀតម្តាយធំខ្ញុំនឹងក៏ខ្ញុំបានទាន់ដង្ហើមរបស់គាត់ដែលពេលនឹងខ្ញុំបានមកផ្ទះវិញនៅ ពេលយប់ហើយដល់ចឹងហើយ១ខែនឹងគេបានហៅទៅប្រជុំ១ដងដំពេលចឹងហើយក៏ទៅប្រជុំ នឹងគេជាមួយនឹងអ្នកថ្មីនឹងអ្នកចាស់នឹងចឹងហើយបានជានាំគ្នាកាលនឹងទៅប្រជុំទាំងអស់គ្នាចឹ ងទៅខ្ញុំនៅផ្ទះនៅមើលគាត់ព្រោះអីកាលនឹងគាត់បានឈឺចឹងទៅគាត់នឹងបានទាលរកអង្រឹង យកមកសំរាប់ដេកកាលនឹងអង្រឹងខ្សែកំផ្លោកយើងនឹង...

ក៖ ចាស!

ខ៖ ហើយកាលនឹងគាត់នឹងក៏បានស្លាប់នៅលើអង្រឹងនឹងតែម្តងទៅចឹងទៅខ្ញុំនឹងក៏បានទៅហៅ ម្តាយខ្ញុំថាម្តាយធំគាត់មានស្លាប់ហើយចឹងទៅម្តាយខ្ញុំនឹងក៏បានយកគាត់មកដើម្បីទៅបូជាតែ ម្តងទៅកាលនឹងព្រោះអីកាលនឹងគេមានយកសពរបស់មនុស្សណាដែលខូត(ស្លាប់)ទៅនឹងគេ បានយកទៅបូជាអោយដែលនោះហើយមុនបូជានឹងគេក៏បានសួរអ្នកដែលត្រូវជាសមាជិកនឹង ថាចង់បូជាឬក៏ចង់កប់ដីបើយើងនឹងចង់បូជាគេយកទៅបូជាអោយបើយើងនឹងចង់យកសពនឹង ទៅកប់ដីគេនឹងយកទៅកប់នៅក្នុងដីអោយយើងទៀត។

ក៖ អូ!

ខ៖ ចាស!

ក៖ ចឹងកន្លែងដែលបានកប់ឬបូជានឹងដែលមានរួមទាំងម្តាយលោកឪពុកនឹងបងប្អូនរបស់អ៊ុំនៅ តែមានចាំកន្លែងដែលពួកគាត់បានបូជាឬក៏កប់នឹងដែលឬទេសព្វថ្ងៃនឹង?

ខ៖ គាត់ចេះទេកាលនឹងម្តាយខ្ញុំនឹងគាត់បានស្លាប់ទៅនឹងនៅក្នុងភូមិក្នុងពេទ្យគេទេនៅជិតភូមិ យើងដែលវាមានប្រវែងជិតភូមិនេះដែលទេប្រវែងពីផ្សារសាមគ្គីយើងនិងហើយពីបុរីពិភពថ្មី យើងនឹងណាកាលនឹងវាប្រវែងនឹងឯកាលនឹងហើយចឹងពេលនឹងខ្ញុំបានដើរពីប្រវែងនឹងទៅ

មើលគាត់ពីភូមិយើងនឹងទៅមន្ទីពេទ្រដែលគាត់បានសំរាក់នៅព្យាបាលជំងឺនឹងចឹងហើយម្ដាយខ្ញុំនឹងគាត់ក៏បានស្លាប់នៅក្នុងមន្ទីពេទ្រនៅក្នុងភូមិគោកថ្មីហើយភូមិរបស់ខ្ញុំដែលយើងរស់នៅនឹងមានឈ្មោះថាភូមិគោកយាងហើយនៅទល់មុខភូមិគោកចាស់កាលនឹងខ្ញុំនឹងបានស្គាល់តែភូមិចឹងទេកាលនឹងនោះខ្ញុំបានស្គាល់តែភូមិចឹងទេកាលនឹងនោះ ហើយចំណែកឯម្ដាយខ្ញុំនឹងកាលដែលគាត់ស្លាប់នឹងគាត់បានស្លាប់នៅពេលដែលមានមាយភ្លៀងហើយផ្គរចឹងហើយពេលនឹងមានទាំងរន្ទះនៅពេលយប់ចឹងទៀតហើយដល់មានហេតុការណ៍ចឹងទៅគេមិនបានអោយខ្ញុំទៅទេកាលនឹងព្រោះអីកាលនឹងខ្ញុំវានៅពាងក្មេងដែលចឹងហើយគេមិនបានអោយខ្ញុំនឹងទៅមើលម្ដាយរបស់ខ្ញុំស្លាប់ទេកាលនឹងនោះហើយពេលនឹងខាងគេមូលដ្ឋាននឹងគេបានសែងសពរបស់គាត់នឹងយកដាក់ប៉ារទៅកប់អោយហើយបានរយៈពេល១០ថ្ងៃនឹងគេបានទៅយកសពទៅកប់នឹងទៀតនឹងគេក៏បានប្រាប់ខ្ញុំថាសពរបស់ម្ដាយឯងនឹងគេឃើញឆ្កែចចកវាបានកាយសពរបស់ម្ដាយឯងនឹងស៊ីដៃគាត់មួយចំហៀងហើយ.

ក៖ ហឺ...!

ខ៖ ចុះកាលនឹងមានឆ្កែចចកព្រៃច្រើនចឹងទៅណាហើយដំតែពេលយើងនឹងទៅកប់ប្រញ៉េមប្រញ៉ាប់ចឹងទៅឆ្កែចចកនឹងវាចេះតែទៅហិតខ្លិនចឹងទៅណាហើយពេលដែលវាឃើញចឹងវាក៏ចេះតែកាយទៅព្រោះវាមានខ្លិនស្អុយចឹងទៅវាក៏ស៊ីសពគាត់ខ្លះៗចឹងទៅដល់ពេលហើយទៅពួកមូលដ្ឋាននឹងមកប្រាប់ចឹងខ្ញុំកាលនឹងដល់ពេលបានលឺចឹងហើយខ្ញុំមិនបានខ្លាចគេយកខ្ញុំនឹងទៅវៃចោលអីទេកាលនឹងនោះខ្ញុំថាអោយវិញ ហើយពេលដែលដឹងថាម្ដាយខ្ញុំស្លាប់ចឹងទៅខ្ញុំចឹងតែយំអើយយំហើយដល់ពេលដែលអ្នកនៅក្នុងពេទ្រនឹងគេមើលឃើញចឹងគេក៏មកប្រាប់ខ្ញុំមីអូនកុំយំប្រយ័ត្នពួកដែលគេនៅទិសនារតីនោះគេឃើញចឹងគេយកឯងទៅវៃចោលទៅ។ដល់ពេលចឹងខ្ញុំនៅតែយំហើយស្រែយំខ្លាំងៗជាងមុនថាគេយកខ្ញុំទៅវៃចោលក៏យកទៅខ្ញុំទៅស្លាប់ជាមួយនឹងម្ដាយរបស់ខ្ញុំយកខ្ញុំទៅវៃចោលក៏ខ្ញុំនឹងមិនខ្លាចដែលព្រោះម្ដាយខ្ញុំស្លាប់ហើយមិនអោយខ្ញុំនឹងយំយ៉ាងម៉េច?ចឹងទៅបានពួកនារតីនឹងគេបានដើរមកគេគ្មានទៅមាត់កអីទេកាលនឹង...

ក៖ ហឺ!.

ខ៖ ហើយពេលនឹងគេគ្រាន់តែថាយកសពរបស់ម្ដាយកុមារនឹងទៅកប់អោយស្រួលបួលវិញទៅចឹងបានថាពេលនឹងគេមកលួងលោមយើងនឹងអោយយើងឈប់យំវិញប៉ុន្តែអ្នកថ្មីនឹងគេបានប្រាប់យើងព្រោះអីខ្លាចគេនិងយកយើងនឹងទៅវៃចោលចឹងទៅណាប៉ុន្តែវាមិនអីដែលកាលនឹងគេមិនបានយកយើងនឹងទៅវៃចោលទេហើយគេបានមកជួយលួងលោមខ្ញុំវិញ។ចឹងកាលនឹងវាចេះតែជួបអ្នកដែលគេចិត្តធម៍បុណ្យដែលកន្លែងដែលយើងនៅនឹងប៉ុន្តែវាលំបាននឹងនៅពេលដែលយើងបានបែកបាក់បងប្អូននឹងឪពុកម្ដាយរបស់យើងនឹងនៅពេលដែលយើងនឹងនៅកាលពីតូចមកនឹងឯងវាលំបាកចឹងយើងមិនបានថៅជុំរុំគ្នាបានមើលឃើញឪពុកម្ដាយយើង យើងធំពេញវ័យចឹងវាមិនបានអស់ចិត្តព្រោះពេលដែលយើងបានធ្វើការធ្វើងារអីចឹងយើងចង់សង់គុណគាត់អោយអស់ចិត្តពីខ្លួនរបស់យើងពីចិត្តយើងសំរាប់គាត់នឹងណាហើយពេលនឹងចឹងមានកំហឹងឈឺចាប់តែត្រង់ចំណុចនឹងទេព្រោះអីយើងចង់អោយមានម្ដាយមានឪពុកបងប្អូនអីអោយដូចគេដែល ព្រោះពេលដែលយើងវាធំទៅយើងអាចធ្វើការសងគុណគាត់នឹងហើយចឹងហើយបានជាពេលនឹងគាត់បានអីព្រោះយើងនឹងនៅតូចយើងមិនទាន់បានធ្វើអីសំរាប់នឹងសងគុណគាត់ផងស្រាប់តែគាត់បានស្លាប់ទៅហើយពេលដែលយើងអាចនឹងសងគុណគាត់បានហើយបែរជាមិនអាចនឹងសងគុណគាត់វិញបានហើយគាត់ស្លាប់នឹងក៏បានធ្វើបុណ្យហៃលសពនឹងដែលប៉ុន្តែវាមិនបានដូចឥឡូវមានលោកមានអាចារ្យអីចឹងកាលនឹងមានតែបានបូជាអីនឹងគ្រាន់តែបានចឹងហើយចឹងហើយនឹងវាបានឈឺចាប់ចឹងឯង.

(សំលេងថៅអ៊ុំយំ)

ហើយបើថានិយាយពីខ្សែជីវិតរបស់មីងនឹងនិយាយទៅវាលំបាករហូតនឹងពិបាកការជំនាន់អាពតចឹងទៅហើយមានទុក្ខលំបាកកាលនឹងមានម្ដាយឪពុកដែលប៉ុន្តែពួកគាត់បានស្លាប់ចោលទៅចឹងទៅកាលនឹងនោះ ហើយពេលដែលមានប្ដីចឹងទៅពេលដេលគេមានចិត្តបុណ្យចឹងទៅមានមួយរយៈទៅហើយពេលណាគេនឹងធ្វើបាបយើងនឹងគេមានមួយរយៈចឹងដែលទៅ...

ក៖ ហឺ.!

ខ៖ ចឹង!ហើយថាអ៊ុំនឹងបានជួបទុក្ខតែរហូតនឹងសព្វថ្ងៃនឹង។

ក៖ ចឹង!កាលនឹងឪពុកម្ដាយជាអ្នកទុកដាក់អោយឬក៏អ៊ុំបានស្រលាញ់គ្នា?

ខ៖ កាលនឹងអ៊ុំបានស្រលាញ់គ្នាព្រោះអីកាលនឹងឪពុកម្ដាយរបស់ខ្ញុំនឹងគាត់បានស្លាប់អស់ហើយនឹងចឹងអ៊ុំនឹងគាត់នឹងបានស្រលាញ់គ្នាដោយចិត្តនឹងចិត្ត ហើយកាលនឹងគេមានបាននៅម្ដាយតែម្ដាយគេមិនបានពេញចិត្តយើងទេតែមានបងនឹងបងប្អូនគេនឹងគេបានមានចិត្តថាចូលចិត្តយើងគេពេញចិត្តយើងចឹងទៅគេនឹងក៏ថាអោយយកយើងចឹងទៅណា សមគេចឹងទៅបានថាខ្ញុំមានទុក្ខលំបាករហូតនឹងរហូតដល់មានកូន ហើយមកពិបាកនឹងមីប្អូនខ្ញុំនឹងដែលវាទឹមតែស្លាប់នឹងទៅនឹងក៏ចឹងដែលខ្ញុំនឹងបានចញ្ចឹមវាផងហើយខ្ញុំនឹងត្រូវទៅចិញ្ចឹមកូនៗខ្ញុំទៀតហើយពេលនឹងខ្ញុំនឹងត្រូវធ្វើការងារនោះដ៏ចឹងទៅបានថា...ខ្ញុំនឹងវាលំបាករហូតនឹង។

ក៖ ហឺ!ចឹងគាត់ស្លាប់ទៅនឹងដោយសារមូលហេតុអ្វីដែលអ៊ុំ?

ខ៖ ប្អូនស្រីខ្ញុំនឹងហ៎?

ក៖ ចាស!

ខ៖ វាផឹកស្រាពេកចឹងហើយខ្ញុំនឹងគេនិយាយអីចឹងហើយនឹងវាមិនស្ដាប់គេទេចឹងហើយពេលវាផឹកនឹងវាបានផឹកពេកវាផឹកនឹងជាងប្រុសគេផឹកទៅណាដល់តែវានឹងមានផ្ទៃពោះហើយនឹងក៏វានៅតែផឹកដល់ចឹងទៅវាខូតគ្រឿងក្នុងចឹងទៅណាវានឹងយ៉ាប់ណាវាផឹកៗស្អីក៏ផឹកដល់ពេលដែលកូននឹងបានកើតហើយក៏វានៅតែផឹកៗដ៏ពេលដេលវាកើតហើយនឹងក៏វានៅតែផឹកៗទៀតនឹងដ៏កើតហើយកាលនឹងផឹករហូតដល់ពេលដែលវានឹងស្លាប់ទៅម៉ង់នឹងវាបានផឹងនឹងវាផឹកលុសខ្សែចឹងទៅណាវាផឹងរហូតដល់ពេលដែលខ្ញុំថាអីក៏វាមិនស្ដាប់ហើយដល់ពេលដែលវានឹងទៅពេទ្យ ពេទ្យគេប្រាប់ថាកុំអោយផឹកវានឹងនៅតែផឹកដល់ចឹងទៅក៏បានជាពេលនឹងទៅពេលម្ដងទៀតនឹងពេទ្យគេថាព្យាបាលនឹងលែងកើតហើយចឹងបានជាគេនឹងថាគេអស់សម្មតិភាពនឹងព្យាបាលទៀតព្រោះអីគ្រឿងក្នុងរបស់វានឹងរលួយអស់ហើយនឹងព្រោះអីកាលនឹងវានឹងបានធ្លាក់ឈាមពេលដែលវានឹងក្អក់មកចឹងដល់ដំណាក់កាលនឹងវាចប់ហើយ។

ក៖ ចាស!ហើយកាលនឹងអ៊ុំស្រីនឹងអ៊ុំប្រុសបានរៀបការជាមួយនឹងគ្នានឹងពេលដែលនៅក្នុងជំនាន់អាពតឬក៏ពេលដែលដាច់ហើយអ៊ុំ?

ខ៖ មកស្រលាញ់គ្នានឹងពេលជំនាន់នេះតើ.

ក៖ ពេលដែលដាច់ហើយ ពេលដែលបានដាច់ជំនាន់អាពតហើយ?

ខ៖ នឹងហើយពេលដែលដាច់ហើយនឹងខ្ញុំមានអាយុ២១ឆ្នាំបានជាមួយនឹងគាត់នឹងពេលនឹងជីវិតនឹងវាទុក្ខរហូត ទុក្ខនៅក្នុងគ្រួសារតែដល់ពេលអ្នកខាងក្រៅគេនឹងគេជួយអាណិតយើងវិញ។

ក៖ ចាស!

ខ៖ អើ!អ៊ុំនឹងទុក្ខលំបាកតែនៅក្នុងគ្រួសារតែមួយមុខទេសព្វថ្ងៃនឹងមានទុក្ខនឹងវាចឹងទៅនេះជាកម្មជីវិតរបស់យើងចឹងណាយើងជួបចឹងទៅយើងនឹងក៏មានលេបទាំងគ្រោះលេបទាំងថ្មចឹងទៅអានឹងទៅវាកម្មយើង។

ក៖ ហើយតើអ៊ុំធ្លាប់មានបទពិសោធន៍នៃជីវិតល្អៗដែលឬទេដែលអ៊ុំធ្លាប់បានចាំកន្លងមក?

ខ៖ បើនិយាយទៅល្អនឹងវារាងភាគតិចណាស់និយាយទៅល្អវាភាគតិចណាស់និយាយទៅនឹងនៅក្នុងខ្សែជីវិតនេះខ្ញុំនឹងនោះបានជួបនោះវាមានតែរឿនលំបានច្រើនតែនិយាយពីរឿងល្អៗនឹងវាមានតិចណាស់ចេះវិញដល់ពេលដែលបានចេញពីជំនាន់ពពតនឹងនៅជាមួយនឹងអ៊ុំស្រីហើយកាលនៅពីក្មេងនឹងអ៊ុំមិនបានទៅរៀនសូត្រអីទេកាលនឹងគិតតែបំរើគាត់រហូតចឹងទៅដល់ពេលដែលយើងនឹងមានគ្រួសារទៅបានជាយើងនឹងចេញពីគាត់ចឹងទៅហើយមានគ្រួសារមួយរយៈនឹងបានចាប់ពីកូន១ទៅកូន២នាក់ចឹងទៅក៏ចាប់ពីនឹងមកទុករហូតទៀតចឹងទៅនិយាយទៅទុក្ខនឹងវាទុក្ខជួបតែរហូតមកនឹងបើរឿងថាល្អសុខសប្បាយនឹងវាមានភាគតិចតែបើថាវាសុខសប្បាយនឹងវាមានភាគច្រើន។

ក៖ ចាស!ចឹងអ៊ុំមានរឿងសប្បាយដែរចឹងអ៊ុំ?

ខ៖ ចាស!

ក៖ ចឹងសប្បាយអីគេខ្លះដែលធ្វើអោយអ៊ុំសប្បាយចិត្តដូចថាពេលដែលអ៊ុំនឹកឃើញពីវានឹកធ្វើអោយអ៊ុំនឹងសប្បាយចិត្តណាអ៊ុំ?

ខ៖ រឿងសប្បាយចិត្តនឹងមានដូចថាប្តីរកបានមកចឹងទៅហើយគេនឹងគេសប្បាយចិត្តជាមួយនឹងយើងចឹងទៅណា។

ក៖ ចាស!

ខ៖ ចាស!ហើយយើងនឹងក៏សប្បាយហើយកូនចៅនឹងក៏វាសប្បាយចិត្តដែលព្រោះអីគេបានមើលឃើញយើងនឹងសប្បាយទៅគេនឹងក៏សប្បាយចិត្តដាក់គ្នាចឹងដែលទៅ ដល់ពេលថ្ងៃណាដែលប្ដីនឹងគេបានធ្វើបាបចិត្តយើងចឹងទៅយើងនឹងក៏កើតទុក្ខចឹងទៀតទៅ។

ក៖ ចឹង!តើអ៊ុំប្រុសគាត់មានដែលវៃអ៊ុំដែលឬទេ?

ខ៖ គាត់ធ្លាប់ចវៃដែលតែវាតិចទូចមិនអត់សោះនោះទេព្រោះកាលដែលគាត់ពេលដែលគាត់មានស្រីមានអីចឹងទៅគាត់បានលាក់យើងមិនបានអោយដឹងថាគាត់នឹងទៅលួចមានស្រីថ្មីនៅកន្លែងផ្សេងទេគាត់បានលាក់យើងនឹងមកទុករហូតហើយគាតបានធ្វើបាបចិត្តយើងខ្លាំងចិត្តទៅហើយគាត់នឹងបានទៅរករឿងធ្វើបាបចិត្តរបស់គាតនឹងខ្លាំងចឹងទៅហើយគាត់នឹងនិយាយអីចេះតែរករឿងយើងចឹងទៅហើយពេលនឹងយើងទ្រាំមវាមិនបានក៏ទៅហៅខាងសមាតិកិច្ចគេយកជួយយើងអោយគេបានជួយដោះស្រាយអោយយើងនឹងចឹងទៅណា។

ក៖ ចាស!

ខ៖ ព្រោះគេនឹងការពារសិទ្ធិមនុស្សអំពើហិង្សាអីចឹងទៅណាកាលនឹងនោះ។

ក៖ ចាស!

ខ៖ ចឹងកាលនឹងអ៊ុំបានអោយគេនឹងមកជួយចូលមកដោះស្រាយអោយយើងចឹងទៅណា។

ក៖ ចាស!

ខ៖ ហើយចឹងទៅបានជាគាត់នឹងវាមិនសូវជារករឿង។

ក៖ ហ៊ឺ!.

ខ៖ បានថាខ្សែជីវិតអ៊ុំនឹងវាលំបាកណាស់វាកើតមកមានខ្សែជីវិតលំបាកខុសគេប៉ុន្តែអ៊ុំចេះតែប្រាប់ខ្លួនឯងថាទោះវាលំបានយ៉ាងណាក៏ដោយក៏អ៊ុំនឹងមិនទៅទន់ទោរទន់ជ្រៀយថាពេលដេលអ៊ុំនឹងលំបាកចិត្តហើយនឹងទៅយកស្រាដាក់មុខដូចជាប្អូនបងនឹងបងធ្វើវាទៅមិនរួចនោះទេអ៊ុំទៅមិនរួចនោះទេ កាលនឹងពេលដែលអ៊ុំនឹងលំបាកប៉ុន្មានក៏អ៊ុំនឹងនៅតែខិតខំធ្វើការងារដែលពេលដែលប្ដីអ៊ុំនឹងគាត់លួចមានស្រីថ្មីនឹងអ៊ុំតស៊ូថាប្ដីទៅណាក៏ទៅអោយតែកូននឹងនៅជុំនឹងអ៊ុំ

ហើយអ៊ុំនឹងទៅធ្វើការបាត់ៗចឹងទៅហើយពេលនឹងអ៊ុំធ្វើការបានលុយមកចឹងហើយបានទិញបាយអីអោយកូនៗហើយពេលដែលមើលឃើញកូនៗនឹងវានៅជុំៗគ្នាចឹងអ៊ុំនឹងគ្រាន់តែមើលឃើញមុខកូនៗនឹងក៏អ៊ុំនឹងសប្បាយចិត្តដែលប៉ុន្តែចំណែកឯចិត្តរបស់អ៊ុំនឹងវិញណាវាផ្សេងទៀតទៅពេលដែលកូនៗនឹងគេបានដេកអស់ហើយនឹងអ៊ុំនឹងចាប់ផ្ដើមនឹកឃើញថាអោយមើលទៅលើដំបូលផ្ទះនឹងវាឡើងលេចធ្លុះអស់ហើយដំបូលផ្ទះនឹងវាឡើងលេចមុខហើយលេចក្រោយចឹងដល់ពេលដែលមេឃនឹងវារកនឹងភ្លៀងមកនឹងអ៊ុំនឹងក៏ទៅហៅកូនៗនឹងអោយមកនៅចំណ្ដាលនឹងជុំគ្នាអោយវានឹងក្រោកឡើងសិនហើយពេលនឹងនាំគ្នានឹងទៅយកផ្លាស់ស្ទិចនឹងការផុនអីនឹងមកដើម្បីនឹងត្រងទឹកភ្លៀងទៅហើយពេលដែលមេឃនឹងវាបានឈប់ភ្លៀងហើយនឹងក៏ទៅជូតកន្លែងសំរាប់អោយកូនៗនឹងវាបានដេកវិញទៅអីៗចឹងទៅអានឹងខ្ញុំនឹងវាក៏បានគិតចឹងឯងហើយក៏ពេលខ្លះនឹងពេលដែលនឹកឃើញដល់កន្លែងនឹងទៅធ្វើអោយខ្ញុំនឹងបាននឹកឃើញទៅវាចេះតែស្រក់ទឹកភ្នែកមក ហើយពេលខ្លះនឹងខ្ញុំនឹងវានឹកឃើញថាខ្ញុំនឹងវានឹកឃើញថាយកអ្នកដែលមានជីវៈភាពស្រដែងគ្នាហើយអោយតែយើងនឹងចេះរកបានមកហើយផ្សំគ្នាទៅខំធ្វើការងារទាំងអស់គ្នាចឹងទៅតែដល់ពេលដែលបានរៀបការរួចហើយនឹងគេនឹងបានបែកឆ្វេងពេលដែលយើងនឹងមានបានបន្ទិចបន្ទួចនឹងហើយនឹង។ចឹងហើយបានថាអ៊ុំនឹងមិនទៅទន់ជ្រាយនោះទេអោយតែថាមានកូនទៅហើយអោយតែកូនៗគេបាននៅជុំជាមួយនឹងអ៊ុំចឹងទៅបានហើយព្រោះអីពេលដែលកូនៗនឹងគេបានចេញទៅធ្វើការងារចឹងទៅគេនឹងក៏ចេះតែណែលនាំចឹងទៅថាម៉ែឯខំហូបទៅកុំពិបាកចិត្តខំហូបទៅកុំអោយយើងនឹងវាឈឺអីចឹងទៅណា....

ក៖ ចាស!

ខ៖ ចឹង!ទៅយើងនឹងក៏លែងគិតលែងអីចឹងទៅក៏ចេះតែតស៊ូចេះតែបានរស់នៅបានចឹងទៅ...

ក៖ ហើយចឹងកាលនឹងធ្វើយ៉ាងម៉េចបានជាអ៊ុំដឹងថាប្ដីអ៊ុំមានស្រីចឹងអ៊ុំ?

ខ៖ កាលនឹងអ្នកធ្វើការងារជាមួយនឹងគាត់នឹងគាត់បានជួយប្រាប់យើងហើយពេលនឹងយើងទៅរកនឹងក៏បានឃើញចឹងមែន។ កាលនឹងអ៊ុំបានទៅផ្ទះគេសួរគេចឹងទៅហើយពេលនឹងគេនឹងគេក៏ចិត្តល្អជាមួយនឹងយើងដ៏ចឹងទៅគេនឹងក៏មិនលាក់អីដែលគេក៏បានប្រាប់យើងដែលនឹងគេប្រាប់យើងថាចឹងៗមួយពីចឹងៗមួយចឹងទៅយើងនឹងក៏ទៅរកហើយតាមដានមើលគាត់ចឹង

ទៅ។ កាលនឹងគាត់នឹងបានយកមីស្រីនឹងយកមកផ្ទះហើយយកមកលាក់នៅជាមួយនឹងគ្នាចឹង ហើយនឹងប៉ុនកាលនឹងគេមានអាទូក្រណាត់ដែលនាំចូលមកពីប្រទេសថៃនឹងណាគេនឹងបាន ដាក់សៀវភៅគ្រួសារនឹងនៅលើកនឹងទូនឹងតែពេលនឹងអីមានមេមាន់វាចេះតែច្រាស់ជ្រួលរក ពងនឹងចឹងហើយវាក៏ជ្រុះមកហើយក៏អ៊ុំនឹងបានរើសមកហើយអោយកូននឹងមើលទៅថាម៉េច ព្រោះអីអ៊ុំនឹងបានមើលឃើញនឹងអ៊ុំបានមើលឃើញរូបមនុស្សរាងចាស់ដល់ចឹងទៅដល់ពេល នឹងឃើញមានរូបនឹងជារូបរបស់ម្ដាយមីស្រីនឹងចឹងហើយទៅបានជាគាត់នឹងបានគប់ពីរូបនឹង មកហើយអ៊ុំនឹងមើលទៅថានៅខេត្តតាកែវហើយដ៏ចឹងទៅអ៊ុំនឹងក៏ទៅសួម៉ូតូដុបទៅជាមួយនឹង គេចឹងទៅហើយពេលដែលទៅនឹងទៅរកដល់ហ្វូសផ្សារខេត្តតាកែវនោះទៀតនឹងហើយពេល ដែលបានសួរទៅក៏រកឃើញចឹងវាឡើងចេស់ ហើយកាលនឹងក៏សួរពេលមុនដំបូងនឹងអាតា យើងនឹងវាលាក់យើងថាម្ដងវាយកតែពេលសួរលើកក្រោយទៀតថាអត់យកទេចឹងហើយគាត់ នឹងចេះតែទៅបាត់ៗចឹងទៅពេលនឹងគាត់ចេះតែមកផ្ទះនឹងបានដេកតែមួយយប់ទេហើយចេះ តែទៅបាត់ៗចឹងទៅហើយស្អែកឡើងនឹងគាត់ចេញទៅបាត់ហើយពេលដែលមកបាន១អាទិត្យ អីនឹងដេកបាន១ថ្ងៃទេគាត់នឹងទៅបាត់ទៀតហើយដល់ពេលចឹងហើយនឹងបានជាអ៊ុំនឹងទៅរក ទាល់តែឃើញ ចឹងហើយនឹងបានជាវានឹងរករឿងអ៊ុំមករករឿងអ៊ុំអីចឹងទៅហើយមកឈ្លោះគ្នា ជាមួយនឹងអ៊ុំចឹងទៅហើយអ៊ុំនឹងក៏បានទៅប្ដឹងនឹងសាមាតិកិច្ចអោយគេជួយដោះស្រាយចឹងទៅ ក៏មិនរវល់ចឹងទៅវានឹងមិនរវល់នឹងចិញ្ចឹមកូនផងទើបនឹងមកនឹងទេពេលនឹងណាសុំវានឹងកូន នឹងបានទៅសុំលុយវានឹងទៅកាត់សក់វានឹងក៏ថាអត់មានលុយដែល។

ក៖ ហ៊ឺ!.

ខ៖ ខ្ញុំនឹងតស៊ូរកតែខ្ញុំអីតែខ្ញុំទេខ្ញុំប្រាប់ទៅខ្ញុំប្រាប់អូនឯងថាចឹងពេលដែលកូននឹងគេបានទៅ ប្រឡងហើយអ៊ុំនឹងបាននឹកខ្លោចចិត្តខ្លួនឯងថាចៀកកូនគេទៅប្រឡងទី១២គេមានម្ដាយឪពុក គេទៅមើលចឹងណាហើយចំណែកឯកូនរបស់អ៊ុំវិញទៅប្រឡងនឹងគ្មាននរណាគេទៅមើលមួយ អ៊ុំបានជិះកង់ទៅនៅសាលានៅឯគល់ស្ពានយើងនឹងពេលនឹងអ៊ុំនឹងជិះកង់បន្ដើរនឹងនឹកឃើញ ក៏ទឹកភ្នែកអ៊ុំនឹងវាហូរមកតាមផ្លូវនឹងបន្ដើរព្រោះនឹកឃើញវាអាណិតកូនយើងថាកូនរៀនទី១២ ហើយគេមានឪពុកម្ដាយគេទៅចាំលើកទឹកចិត្តតែកូនខ្ញុំវិញគ្មានឪពុកម្ដាយណាទៅចាំលើកកំ លាំងចិត្តនោះទេ...

ក៖ ហ៊ឺ!.

ខ៖ គ្មាននរណាគេបានទៅលើទឹកចិត្តទេកូននឹងវាបានទៅប្រឡងហើយនឹងហើយកាលនឹងវានឹងចេះតែប្រឡងជាប់នឹងគេដែលកាលនឹងហើយកាលនឹងនោះមានមិត្តភក្តិគេម្នាក់មកប្រាប់ថាម៉ែៗអាបងគាត់អត់លុយទេម៉ែគាត់មានលុយទៅសំរាប់ការប្រឡងនោះទេហើយពេលនឹងគេមានមិត្តរបស់គេម្នាក់នឹងទៅដើរប្រាប់គ្នាគេថាកូនអ៊ុំនឹងអត់មានលុយសំរាប់មកប្រឡងទេចឹងហើយពេលនឹងគេនឹងក៏បានមកថ្នាក់វិញហើយដើរប្រាប់មិត្តភក្តិគេផ្សេងៗទៀតថាកូនអ៊ុំនឹងត្រូវការលុយចឹងហើយគេនឹងក៏បានដើររៃលុយគ្នាក្នុង១បាន៥០០រទៅ១០០០រអីដែលចឹងទៅណាកាលនឹងនោះគេបានរៃលុយអោយមកកូនយើងណា.

ក៖ ចាស!

ខ៖ ចឹង!ហើយបានថាវាយ៉ាបណាស់

ក៖ ចឹង!ហើយពេលឥឡូវគាត់បានរៀនចប់ចឹងគាត់បានចូលធ្វើការងារដែរឬទេ?

ខ៖ ឥឡូវនឹងគេបានចូលធ្វើការនៅខាងជាងភ្លើងនឹងណាមានដូចជាការជួសជួសទូរទឹកកកម៉ាស៊ីនភ្លើងអីនឹងដែលនឹងហើយពេលដែលបានការងារនឹងធ្វើនឹងក៏ដោយសារតែមានអង្គការមួយគេបានមកប្រាប់ដំណឹងដ៏កូនអ៊ុំអាប្រុសនឹងពេលនឹងគេបានមករើសនៅដ៏ភូមិអ៊ុំនឹងតែម្តងហើយកូនអ៊ុំនឹងវាខំប្រឹងរៀនរហូតដល់បានប្រឡងជាប់របស់វាចឹងដែលទៅ ហើយពេលនឹងគេនឹងបានជួយជាសំភារៈជាម៉ាស៊ីភ្លើងចឹងអោយយើងដែលចឹងទៅណាកាលនឹងនោះហើយកាលនឹងនៅក្នុងភូមិនេះនឹងគេមាននៅខ្វះដូចជាជាងធ្វើម៉ាស៊ីនភ្លើងនឹងទូរទឹកកកនឹងចឹងហើយក៏គេនឹងមានជ្រើសរើសជាងបន្ថែមចឹងទៅហើយយើងនឹងក៏ចេះតែបានដើរអែបៗគេចឹងទៅណាកាលនោះវាចឹងហើយពេលនឹងមានសំណាងល្អដែលព្រោះមានគេដែលបានធ្វើការនៅក្នុងនឹងគេនឹងវាឈប់ធ្វើការងារនឹងទៅហើយវានឹងក៏បានចូលទៅបំពេញកន្លែងរបស់គេនឹងដែលកាលនឹងនោះហើយកាលនឹងវានឹងបាននៅជាប់ជាមួយនឹងថៅកែគេនឹងចឹងទៅឥឡូវនឹងវានឹងបានរាងរឹងមាំងនឹងគេដែលឥឡូវនឹងសំរាប់ការងាររបស់វានឹងនោះ។

ក៖ ចាស!ចឹងការងារនឹងគាត់បានធ្វើហើយអាចចិញ្ចឹមខ្លួនឯងបានហើយឬនៅ?

ខ៖ អូ!ឥឡូវនឹងវាមានចិញ្ចឹមខ្លួនឯងបានហើយ ហើយឥឡូវនឹងវានឹងពេលខ្លះទៅវាមានបានអោយយើងនឹងបានចាយដែលនឹងពេលដែលវានឹងបានបើកប្រាក់ខែមកម្តងៗនឹងឯ ហើយ

ពេលដែលឪវាឈប់ផ្លួតចឹងទៅក៏កូនចៅនឹងវាបានរាងគ្រាន់បើហើយកូនចៅនឹងវាមានសភាពល្អជាងមុននឹងចឹងហើយកូនៗនឹងវាមានការងារធ្វើចឹងដែលនឹងបានធ្វើអោយវានឹងនៅមានកំលាំងហើយរាងគ្រាន់បើដែលទៅ និយាយទៅអ៊ុំនឹងវាពិបាកណាស់នរណាគេក៏គេនឹងមើលឃើញដែលសភាពផ្ទះរបស់អ៊ុំកាលពីមុននឹងតែដល់ពេលឥឡូវនឹងទៅអ្នកភូមិនៅជិតៗនឹងគេបានស្ងោតសរសើរអ៊ុំបានមានជីវភាពរាងប្រសើរជាងមុនហើយដំពេលឥឡូវនឹងវាផ្ទុយគ្នាវិញចឹងព្រោះអីទៅជាអ៊ុំនឹងមានជីវៈភាពរាងគ្រាន់បើតែចំណែកឯខាងគេនឹងបែរជាមានជីវៈភាពរាងមើលទៅរាងយ៉ាប់ជាងអ៊ុំវិញចឹងបានថានេះរឿងខ្សែជីវិតវាមិនទៀងទេម្តងឡើងម្តងចុះចឹងឯងណាដឹងវាចឹងណា ថាឥឡូវនឹងអ៊ុំបានតែប៉ុណ្ណឹងក៏អ៊ុំបានសប្បាយចិត្តដែលព្រោះអីសព្វថ្ងៃនឹងអ៊ុំមានកូនៗគេបានហុចលុយអោយអ៊ុំម្នាក់បានបន្តិចៗទៅចឹងណាហើយពេលដឹងនឹងមានរឿងល្អៗចឹងកូនគេសប្បាយចិត្តចឹងបានប៉ុន្មានមកនឹងអ៊ុំនឹងក៏បានទុកសំរាប់ពេលក្រោយអ៊ុំនឹងបានចេះតែទុកសំរាប់សន្សំទៅលុយនឹងដែលគេបានអោយអ៊ុំនឹងនោះ។

ក៖ ចាស! ចឹងអ៊ុំមានកូនៗសុទ្ធតែកន្លងធម៌?

ខ៖ ចាស! ប៉ុន្តែមានតែកូន៣នាក់ទេដែលគេនឹងប្រកបដោយកន្លងធម៌ចំណែកឯកូន១ទៀតនឹងវាបង្កើតអោយអ៊ុំនឹងមានទុក្ខណាស់វានឹងបានធ្វើអោយយើងនឹងរំពុលទុក្ខណាស់ប៉ុន្តែចំណែកឯកូនៗអ៊ុំ៣នាក់ទៀតនឹងគេមានអីចឹងគេបានគិតឃើញយើងជាម្តាយគេបានអោយយើងហើយ។

ក៖ ចឹងគាត់ទាំងអស់គ្នានឹងសុទ្ធតែមានការងាររាងៗខ្លួនអស់ហើយអ៊ុំណ៎?

ខ៖ ចាស!ពួកគេនឹងសុទ្ធតែមានការធ្វើរាងៗខ្លួនគេធ្វើអស់ហើយនិយាយទៅនេះកូននេះត្រូវជាម្តាយរបស់វានេះគេជាអ្នកដែលក្រង់កន្ទ្រក់លក់ដែលនឹង ហើយមាន១ទៀតនឹងគេនឹងនៅផ្ទះព្រោះអីឥឡូវនឹងគេមានផ្ទះពោះហើយគេមានពពោះនឹងវាធំចឹងឯហើយប្តីរបស់កូននឹងគេធ្វើជាជាងភ្លើងម៉ាស៊ីនត្រជាក់ដូចគ្នានឹងកូនប្រុសរបស់ខ្ញុំនឹងដែលនឹងព្រោះគេទាំងពីរនាក់នឹងគេជាមិត្តភក្តិនឹងគ្នាជាមួយនឹងកូនខ្ញុំអាប្រុសនឹងចឹងទៅហើយបានគេនឹងបានស្គាល់គ្នានឹងកូនស្រីរបស់ខ្ញុំនឹងដែលនឹង។

ក៖ ចាស!អ៊ុំនិយាយទៅជីវិតវាចឹងឯងអ៊ុំគេថាជីវិតវាជាការតស៊ូ។

ខ៖ ចាស!ចឹងហើយប៉ុន្តែអ៊ុំសូមកាត់ពាក្យតិចជីវិតគឺជាការតស៊ូនឹងហើយប៉ុន្តែគេនឹងមិនតស៊ូដូចជាអ៊ុំនោះទេព្រោះអីជីវិតរបស់អ៊ុំនឹងគឺវាតស៊ូហើយនឹងត្រូវតែអត់ធ្មត់ណាស់ អ៊ុំណាសុទ្ធចិត្តតស៊ូដើរតាមតែផ្លូវល្អទេ ហើយបើផ្លូវអាក្រក់ភ្លេចកូនភ្លេចចៅអីនឹងអ៊ុំមិនយកទេ នែអ៊ុំប្រាប់ទៅខ្លះគេនឹងគេវាមានជីវិតវាពិបាកតែគេនឹងរឹតតែរកផ្លូវទៅបន្ថែមទុក្ខដាក់ខ្លួនគេចឹងដែលទៅគេធ្វើអោយខ្លួនរបស់គេនឹងទៅជាទន់ជ្រៀយបន្ថែមទៀតដូចជាក់ស្តែងដូចជាប្អូនរបស់អ៊ុំនឹងក៏ចឹងដែរដែលវានឹងទឹងតែស្លាប់នឹងដែលនឹងវានឹងដឹងថាខ្លួននឹងវាអត់ហើយនឹងវាននៅតែយកស្រាធ្វើជាត្រីមុខហើយវានឹងផឹកទៅត្រូវស្រវឹកដើរដេកដួលនៅតាមផ្លូវហើយពេលខ្លះនឹងវានឹងត្រូវឈឺខ្លួនឯងនឹងវាទុក្ខលើសដើមវាមិនរកវិធីអីវាគិតពេលដែលវានឹងស្រវឹកចឹងទៅធ្វើអោយវានឹងលែងគិតចឹងហើយពេលដែលបាត់ស្រវឹកនឹងមិនទាន់នោះទេវានឹងទៅរកទិញស្រាយនឹងនៅនឹងកន្លែងទាមកន្លែងគេលក់ស្រាចឹងទៀតទៅវានឹងយកទុក្ខដាក់នៅក្នុងខ្លួនឯងណាស់តែចំណែកអ៊ុំវិញណាពេលដែលអ៊ុំនិងមានទុក្ខអ៊ុំនឹកគិតតែមួយនោះទេថាអ៊ុំត្រូវតែខិតខំធ្វើការងារហើយអ៊ុំនឹងត្រូវតែរកលុយយ៉ាងណាដើម្បីនឹងចិញ្ចឹមកូនៗមិនអោយទៅដើរសុំគេនឹងទេហើយអ៊ុំនឹងណាខំធ្វើយ៉ាងណាអោយកូននឹងបានអីស៊ីនឹងគេតែគ្រាន់តែថាវាមិនបានមានលុយនឹងដើរទិញសំលៀកបំពាក់អីដែលស្អាតៗនឹងគេអ៊ុំនឹងបានត្រឹមតែមិនអោយខោអាវនឹងវាពាក់ទៅរហែតលេចលើលេចក្រោមទៅវាបានហើយ នឹងកុំអោយតែយើងនឹងមានខ្លិនស្អុយអាក្រក់ដើរទៅជិតគេនឹងវាមិនបានទៅបានហើយ។

ក៖ ថាត្រូវហើយអ៊ុំហើយខ្ញុំសូមសរសើរដ៏អ៊ុំដែលបានខិតខំប្រឹងប្រែងចិញ្ចឹមថែរក្សាកូនៗរហូតដល់ពួកគាត់នឹងបានធំៗទាំងអស់គ្នាហើយពួកគាត់នឹងបានរៀននឹងបានធ្វើការងារទាំងអស់គ្នាទៀត ចាសហើយចឹងតើអ៊ុំមានប្រសាសជាចុងក្រោយដើម្បីនឹងផ្តែផ្តាំដល់អ្នកជំនាន់ក្រោយដែលគាត់បានស្តាប់សំលេងរបស់អ៊ុំ?

ខ៖ ចាស!អ៊ុំចង់ផ្តែផ្តាំបងប្អូនទាំងអស់គ្នាថាសូមអោយបងប្អូនទាំងអស់គ្នានឹងយកគំរូណាដែលល្អៗបានហើយតែបើថាមានទុក្ខលំបាកយ៉ាងណាកុំអោយយកអារឿងណាដែលវាអាក្រក់ៗមកដាក់នឹងខ្លួនឯងអីយកតែរឿងណាល្អៗយកវាមកទុកនឹងដាក់នៅនឹងក្នុងជីវិតរបស់យើងចឹងទៅហើយបើមានក្រុមគ្រួសារត្រូវតែមានមេតាដល់កូនចៅនឹងទៅចេះណែនាំវាហើយធ្វើអំពើល្អៗហើយប្រានប្រដៅវាចឹងទៅធ្វើយ៉ាងម៉េចបើវានឹងត្រូវជាកូនចៅរបស់យើងហើយនឹងហើយសុំ

ជួយជុំរុញវាបន្ថែមកុំទៅជុំរុំវានឹងខាងឯផ្លូវណាដែលអាក្រក់អីសូមជួយប្រាប់វាអោយដើរតាមផ្លូវល្អហើយនឹងចេះលើកទឹកចិត្តវាចឹងទៅអ៊ុំមានតែប៉ុណ្ណឹងនោះទេ។

ក៖ ចាស!ចឹងអរគុណអ៊ុំសូមជូនពរអោយអ៊ុំមានសុខភាពល្អនឹងក្រុមគ្រួសារមានសុភមង្គលទាំងអស់គ្នា។

ខ៖ ចាស!